# នៅចំពោះមុខ អង្គជំនុំជម្រះសាលាដំបូង
# អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

## ព័ត៌មានពិស្តារអំពីការដាក់ឯកសារ

សំណុំរឿងលេខ: ០០២/១៩-០៩-២០០៧-អ.វ.ត.ក/អ.ជ.ស.ដ

ភាគីដាក់ឯកសារ: សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី

ដាក់ជូន: អង្គជំនុំជម្រះសាលាដំបូង

ភាសាដើម: អង់គ្លេស

កាលបរិច្ឆេទឯកសារ: ថ្ងៃទី ២០ ខែ មិថុនា ឆ្នាំ ២០១៦

ឯកសារបកប្រែ
TRANSLATION/TRADUCTION
ថ្ងៃ ខែ ឆ្នាំ (Date): 08-Jul-2016, 13:07
CMS/CFO: Sann Rada

## ចំណាត់ថ្នាក់ឯកសារ

ចំណាត់ថ្នាក់ឯកសារ ស្នើឡើងដោយភាគីដាក់ឯកសារ: សាធារណៈ

ចំណាត់ថ្នាក់ឯកសារដោយអង្គជំនុំជម្រះ **សាធារណៈ/Public**

ឋានៈនៃចំណាត់ថ្នាក់ឯកសារ

ពិនិត្យឡើងវិញចំពោះឯកសារចំណាត់ថ្នាក់បណ្តោះអាសន្ន:

ឈ្មោះមន្ត្រីកត់ត្រា:

ហត្ថលេខា:

---

**ចម្លើយតបរបស់សហមេធាវីនាំមុខ ទៅនឹងសារណារបស់ នួន ជា ស្តីពីភាពពាក់ព័ន្ធនៃភស្តុតាងអំពីការបះបោរក្បត់ ទៅនឹងការទទួលខុសត្រូវព្រហ្មទណ្ឌរបស់គាត់ក្នុងសំណុំរឿង ០០២/០២**

---

**ដាក់ដោយ៖**

**សហមេធាវីនាំមុខដើមបណ្តឹងរដ្ឋប្បវេណី៖**

ពេជ អង្គ

Marie GUIRAUD

**សហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី៖**

ជេត វណ្ណលី

ហុង គឹមសួន

គឹម ម៉េងឃី

ឡោ ជុនធី

ម៉ុច សុវណ្ណារី

ស៊ិន សុវ៉ន

សំ សុគង់

**នៅចំពោះមុខ៖**

**អង្គជំនុំជម្រះសាលាដំបូង៖**

ចៅក្រម និល ណុន ជាប្រធាន

ចៅក្រម យ៉ា សុខន

ចៅក្រម Jean-Marc LAVERGNE

ចៅក្រម យូរ ឧត្តរា

ចៅក្រម Claudia FENZ

**ផ្ញើជូន៖**

**ការិយាល័យសហព្រះរាជអាជ្ញា៖**

ជា លាង

Nicholas KOUMJIAN

វ៉េន ពៅ

ទី ស្រីនណា

Laure DESFORGES
Ferdinand DJAMMEN NZEPA
Isabelle DURAND
Françoise GAUTRY
Emmanuel JACOMY
Martine JACQUIN
Yiqiang Y. LIU
Daniel LOSQ
Christine MARTINEAU
Lyma NGUYEN
Mahesh RAI
Nushin SARKARATI

**ជនជាប់ចោទ៖**

ខៀវ សំផន

នួន ជា

**សហមេធាវីការពារក្តី៖**

សុន អរុណ

Victor KOPPE

គង់ សំអុន

Anta GUISSÉ

**មេធាវីប្រចាំការ៖**

ទូច វរល័ក្ស

Calvin SAUNDERS

**សហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី៖**

Olivier BAHOUGNE
Patrick BAUDOUIN
Beini Ye

# I. សេចក្ដីផ្ដើម

1. បន្ទាប់ពីបានទទួលការណែនាំរបស់អង្គជំនុំជម្រះសាលាដំបូង[1] សហមេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណី ("សហមេធាវីនាំមុខ") សូមឆ្លើយតបសារណារបស់មេធាវីការពារក្ដី នួន ជា ស្ដីពីភាពពាក់ព័ន្ធនៃភស្តុតាងអំពីការបះបោរក្បត់ ទៅនឹងការទទួលខុសត្រូវព្រហ្មទណ្ឌរបស់គាត់ ក្នុងសំណុំរឿង ០០២/០២[2]។

# II. ច្បាប់ជាធរមាន

2. នៅថ្ងៃទី ១៧ ខែ មករា ឆ្នាំ ២០១១ នៅពេលដែលអង្គជំនុំជម្រះសាលាដំបូងបានស្នើសុំឲ្យភាគីដាក់សម្ភារៈរបស់ខ្លួន អនុលោមតាមវិធាន ៨០ នៃវិធានផ្ទៃក្នុង អង្គជំនុំជម្រះបានពន្យល់ថា ភាគីត្រូវផ្ដល់ព័ត៌មានដូចខាងក្រោមនេះ៖

> "i) សេចក្ដីសង្ខេបនៃអង្គហេតុដែលសាក្សីនឹងត្រូវធ្វើសក្ខីកម្ម ឬសេចក្ដីសង្ខេបអង្គហេតុដែលដើមបណ្ដឹងរដ្ឋប្បវេណីនីមួយៗនឹងមកធ្វើសេចក្ដីថ្លែងការណ៍ ឬអង្គហេតុដែលមានផលប៉ះពាល់ទៅនឹងបទចោទនីមួយៗ។ ដោយវិធានការការពារអាចត្រូវដាក់ចេញ ឬដោយមិនទាន់បានពិចារណាដោយអង្គជំនុំជម្រះ សេចក្ដីសង្ខេបនោះត្រូវមានភាពលម្អិត គ្រប់គ្រាន់ដែលអាចឲ្យអង្គជំនុំជម្រះ និងភាគីអាចយល់បានពេញលេញនូវលក្ខណៈ និងខ្លឹមសារនៃសក្ខីកម្មដែលបានស្នើសុំនោះ។
>
> ii) សេចក្ដីសង្ខេបអំពីភាពជំនាញរបស់អ្នកជំនាញ និងគុណវុឌ្ឍិរបស់អ្នកជំនាញនីមួយៗដែលបានស្នើសុំ។ ដោយវិធានការការពារអាចត្រូវដាក់ចេញ សេចក្ដីសង្ខេបនេះត្រូវមានភាពលម្អិតគ្រប់គ្រាន់ដែលអាចឲ្យអង្គជំនុំជម្រះ ឬភាគីអាចយល់បានពេញលេញនូវលក្ខណៈ និងខ្លឹមសារនៃភាពជំនាញរបស់អ្នកជំនាញ ដែលបានស្នើសុំនោះ និង

---

[1] សំណើសុំសារណាសង្ខេបស្ដីអំពីសារៈសំខាន់នៃក្រុមជម្លោះនៅក្នុងថ្នាក់ដឹកនាំកម្ពុជាប្រជាធិបតេយ្យ, ឯកសារ E395/1, ថ្ងៃទី ១១ ខែ ឧសភា ឆ្នាំ ២០១៦ ("សំណើសុំការបញ្ជាក់បំភ្លឺ") កថាខណ្ឌ ៥។

[2] សេចក្ដីសន្និដ្ឋានរបស់ នួន ជា ស្ដីពីភាពពាក់ព័ន្ធនៃភស្តុតាងស្ដីពីការបះបោរក្បត់ទៅនឹងការទទួលខុសត្រូវព្រហ្មទណ្ឌរបស់គាត់ ក្នុងសំណុំរឿង ០០២/០២, ឯកសារ E395/2, ថ្ងៃទី ១០ ខែ មិថុនា ឆ្នាំ ២០១៦ (សារណា)។

iii) ចំណុចនៃការចោទប្រកាន់ ដែលសាក្សី ដើមបណ្តឹងរដ្ឋប្បវេណី ឬអ្នកជំនាញដែលបានស្នើសុំនោះ រំពឹងថានឹងមកផ្តល់សក្ខីកម្ម ហើយត្រូវបញ្ជាក់ផងដែរនូវលេខកថាខណ្ឌនៃដីកាដំណោះស្រាយ និងបទចោទជាក់លាក់ណាមួយ”[3]។

3. វិធាន ៨៧(៤) នៃវិធានផ្ទៃក្នុង ផ្តល់សិទ្ធិទៅអង្គជំនុំជម្រះក្នុងការកោះហៅ ឬស្តាប់សក្ខីកម្មបុគ្គលនានា ក្នុងនាមជាសាក្សី ដែលភស្តុតាងរបស់ជននោះត្រូវបានចាត់ទុកថាអាចនាំទៅរកការបញ្ជាក់ការពិតបាន បន្ទាប់ពីមានសំណើដែលមានសំអាងហេតុពីភាគីនៃកិច្ចដំណើរការនីតិវិធី។ វិធានដដែលបានបង្កើតលក្ខខណ្ឌដូចមានចែងក្នុងវិធាន ៨៧ (៣) សម្រាប់សំណើនេះ ដោយបានកំណត់ *ក្នុងចំណោមប្រការផ្សេងៗ* ថា សក្ខីកម្មនេះមិនត្រូវ “មិនពាក់ព័ន្ធ ឬច្រំដែល” ឡើយ[4]។ លើសពីនេះទៀត ភាគីស្នើសុំក៏ត្រូវធ្វើឲ្យអង្គជំនុំជម្រះជឿជាក់ថា សក្ខីកម្មដែលបានស្នើសុំ ពុំអាចរកបានមុនពេលបើកការជំនុំជម្រះទេ[5]។

4. អង្គជំនុំជម្រះសាលាដំបូងពីពេលមុនបានបដិសេធមិនកោះហៅបុគ្គលនានាដែលខ្លួនយល់ឃើញថាសក្ខីកម្មពីបុគ្គលដែលបានស្នើសុំនោះ (i) ទំនងជាច្រំដែលជាមួយសក្ខីកម្មរបស់សាក្សីដែលបានផ្តល់សក្ខីកម្មរួចហើយ[6] (ii) មិនផ្តល់ពន្លឺអំពីតួនាទីរបស់ជនជាប់ចោទទាក់ទងហេតុការណ៍ពាក់ព័ន្ធ[7] (iii) ទំនងត្រឹមជាការបញ្ជាក់ និងមិនចាំបាច់ត្រូវស្តាប់នៅសវនាការឡើយ[8] (iv) ឬច្រំដែលជាមួយនឹងភស្តុតាងដទៃទៀតនៅចំពោះមុខអង្គជំនុំជម្រះ[9]។

---

[3] ដីកាបង្គាប់ឲ្យភាគីដាក់សម្ភារៈដើម្បីរៀបចំសវនាការ, ឯកសារ E9, ថ្ងៃទី ១៧ ខែ មករា ឆ្នាំ ២០១១, កថាខណ្ឌ ៦។ សូមមើលឧបសម្ពន្ធ ១-បញ្ជីនៃអង្គហេតុដែលត្រូវបញ្ជាក់ដោយភស្តុតាង, ឯកសារ E9.1, ថ្ងៃទី ១៧ ខែ មករា ឆ្នាំ ២០១១។

[4] វិធានផ្ទៃក្នុង ៨៧(៣)(ក)។ *សូមមើលផងដែរ* សំណុំរឿង០០២/០១, ឯកសារ E312, ថ្ងៃទី ៧ ខែ សីហា ឆ្នាំ ២០១៤ (“សាថាថាស), កថាខណ្ឌ ១២៤។ E188, ថ្ងៃទី ២៦ ខែ កក្កដា ឆ្នាំ ២០១០, កថាខណ្ឌ៤១។

[5] វិធានផ្ទៃក្នុង៨៧(៤)។

[6] សេចក្តីសម្រេចស្តាពរលើសាក្សី អ្នកជំនាញ និងដើមបណ្តឹងរដ្ឋប្បវេណី ក្នុងសំណុំរឿង ០០២/០១, កថាខណ្ឌ ៧១។

[7] ដូចឯកសារយោងខាងលើ កថាខណ្ឌ ៧៥។

[8] ដូចឯកសារយោងមុន។

[9] ដូចឯកសារយោងខាងលើ កថាខណ្ឌ ៧៥, ៧៨, ៨២, ១៣៣។

5. អនុលោមតាមវិធាន ៨៥ ប្រធានត្រូវធានាដល់ការអនុវត្តសិទ្ធិការពារខ្លួនឲ្យប្រព្រឹត្តទៅបានដោយសេរី និងអាចបដិសេធនូវរាល់នីតិវិធីដែលនាំឲ្យមានការពន្យារពេលដល់ការជំនុំជម្រះ និងដែលមិនអាចនាំទៅដល់ការស្វែងរកការពិត។

## III. ចម្លើយតប

6. សហមេធាវីនាំមុខកត់សម្គាល់ឃើញថា សារណានេះរៀបរាប់ និងគូសបញ្ជាក់អំពីសារណាមុនៗរបស់មេធាវីការពារក្តី នួន ជា ដែលក្នុងនោះមានការពិភាក្សាអំពីទ្រឹស្តីទាក់ទងនឹងលក្ខណៈនៃការបែកបាក់ផ្ទៃក្នុងរបស់ ប.ក.ក[10]។ ទោះបីជាមានការលើកឡើងជាច្រើនដងពីសារណាខ្លួននេះក៏ដោយ ក៏សហមេធាវីនាំមុខសូមបញ្ជាក់សម្រាប់គោលបំណងនៃចម្លើយតបនាពេលនេះ (និងគោលបំណងនៃសំណើទីមួយ)[11] ថា បញ្ហានៅចំពោះមុខសម្រាប់សារណានេះ គឺពុំមែនកង្វះភាពលម្អិតនៃ "ការការពារក្តីរបស់មេធាវី" ចំពោះភាគីឡើយ ប៉ុន្តែជាការមិនបំពេញលក្ខខណ្ឌតម្រូវនៃវិធាន៨៧ (៤) និងវិធាន ៩៣។

7. សារណានេះមានគោលបំណងឆ្លើយតបទៅនឹងសំណើរបស់អង្គជំនុំជម្រះសាលាដំបូងឲ្យ "ពន្យល់បន្ថែមថាតើអត្ថិភាពនៃក្រុមដែលមានជម្លោះ អាចផ្តល់ការការពារចំពោះបទចោទក្នុងដីកាដំណោះស្រាយ ឬអាចត្រូវបានចាត់ទុកជាស្ថានសម្រាលទោសដោយវិធីណា"[12]។ សហមេធាវីនាំមុខសូមអះអាងថា សារណានេះខកខានពុំបានធ្វើដូច្នេះ ទាំងក្នុងទម្រង់ និងជាគោលការណ៍។ សហមេធាវីនាំមុខយល់ថា គោលបំណងនៃសំណើរបស់អង្គជំនុំជម្រះសាលាដំបូងឲ្យមានការបញ្ជាក់ និងសំណើផ្សេងៗជាមូលដ្ឋានរបស់មេធាវីការពារក្តី នួន ជា គឺជាបញ្ហាច្បាប់នីតិវិធី និងការបំពេញលក្ខខណ្ឌអប្បបរមានៃភាពអាចទទួលយកបាននៃភស្តុតាង។ សហមេធាវីនាំមុខសូមអះអាងថា ទទ្ធីករណ៍សំខាន់ក្នុងសារណានេះ ពុំឆ្លើយតបទៅនឹងលក្ខខណ្ឌតម្រូវផ្នែកនីតិវិធីនៃវិធាន៨៧(៤) ដែលជាមូលដ្ឋាននៃការបញ្ជាក់នេះឡើយ។ ហេតុដូចនេះ សហមេធាវីនាំមុខមិនផ្តល់យោបល់ស្តីពីការបកស្រាយភស្តុតាង បញ្ហានានានៃលក្ខខណ្ឌតម្រូវគតិយុត្តិនៃឧក្រិដ្ឋកម្មសំខាន់ៗដែលត្រូវបាន

---

[10] សារណា, កថាខណ្ឌ ៩-១៥។

[11] ចម្លើយតបរបស់សហមេធាវីនាំមុខទៅនឹងសំណើទីមួយរបស់ នួន ជា អនុលោមតាមវិធាន៨៧(៤) និងវិធាន៩៣ ទាក់ទងការជំនុំជម្រះលើសំណុំរឿង០០២/០២ ស្តីពីមន្ទីរសន្តិសុខ និងការបោសសម្អាតផ្ទៃក្នុង, ឯកសារ E391/1, ថ្ងៃទី ៤ ខែ មេសា ឆ្នាំ ២០១៦។

[12] សំណើសុំការបញ្ជាក់បំភ្លឺ, កថាខណ្ឌ ៣។

ចោទប្រកាន់ ឬការយោងនានាចំពោះចម្លើយរបស់ នួន ជា អំពីខ្លឹមសារនៃគោលនយោបាយនេះឡើយ។

8. ជាគោលការណ៍ សហមេធាវីនាំមុខពុំជំទាស់ទៅនឹងសំណើសុំភស្តុតាងពាក់ព័ន្ធនឹងជួយដល់ការបញ្ជាក់ការពិតទេ ដរាបណាមានការគោរពតុល្យភាពនៃសិទ្ធិរបស់ភាគី និង/ឬសំណើសុំភស្តុតាងដែលមេធាវីការពារក្តីអះអាងថាជាភស្តុតាងដោះបន្ទុក។ ដើមបណ្តឹងរដ្ឋប្បវេណីយល់ឃើញថា វាជាផលប្រយោជន៍របស់ខ្លួនក្នុងការមានការគោរពពេញលេញចំពោះសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌របស់ជនជាប់ចោទ។ សម្រាប់គោលបំណងនេះ ជាការអនុវត្ត សហមេធាវីនាំមុខសូមទុកភារកិច្ចនេះឲ្យអង្គជំនុំជម្រះសាលាដំបូងជាអ្នកសម្រេចអំពីភាពចាំបាច់ក្នុងការកោះហៅសាក្សីដែលត្រូវបានស្នើសុំ[13]។ ហេតុដូច្នេះ ចំពោះការសម្រេចលើសំណើទីមួយដែលសហមេធាវីនាំមុខពុំបានឆ្លើយតបលើអង្គសេចក្តី និងផ្នែកសេសសល់នៃសំណើសុំភស្តុតាងបន្ថែមដែលអាចត្រូវបានដាក់ សហមេធាវីនាំមុខសូមអះអាងដូចខាងក្រោម។

**(ក) ចម្លើយតបទៅនឹងអត្ថិភាពនៃ "ការការពារក្តីរបស់មេធាវី"**

9. សហមេធាវីនាំមុខសូមអះអាងថា ចំណុចសំខាន់នៃសារណានេះ ផ្អែកជាទូទៅលើការភ័ន្តច្រឡំជាសារវន្តអំពីក្របខណ្ឌគតិយុត្តិនៃ អ.វ.ត.ក និងអំពីប្រព័ន្ធច្បាប់ civil law។

10. សហមេធាវីនាំមុខកត់សម្គាល់ដោយការព្រួយបារម្ភអំពីការប្រើប្រាស់ជាញឹកញាប់នូវពាក្យ "សំណុំរឿងមេធាវីការពារក្តី"[14] ដែលជាពាក្យមួយដែលជាទូទៅគ្មានក្នុងក្របខណ្ឌគតិយុត្តិ អ.វ.ត.ក ច្បាប់កម្ពុជា ច្បាប់បារាំង និងក្នុងច្បាប់ civil law[15]។ បើទោះបីជា កិច្ចដំណើរការនិតិវិធីត្រូវបាន

---

[13] សម្រាប់សាក្សី និងដើមបណ្តឹងរដ្ឋប្បវេណីដែលត្រូវបានស្នើសុំមួយចំនួន សហមេធាវីនាំមុខបានដាក់ចម្លើយតបជាក់លាក់។ *សូមមើល* ចម្លើយតបរបស់សហមេធាវីនាំមុខទៅនឹងសំណើទីពីរ និងទីបីរបស់ នួន ជា ស្តីពីមន្ទីរសន្តិសុខ និងការបោសសម្អាតផ្ទៃក្នុង, E392/1, ថ្ងៃទី ២១ ខែ មេសា ឆ្នាំ ២០១៦។ ចម្លើយតបរបស់សហមេធាវីនាំមុខទៅនឹងសំណើលើកទីបួនរបស់ នួន ជា ស្តីពីមន្ទីរសន្តិសុខ និងការបោសសម្អាតផ្ទៃក្នុង, ឯកសារ E412/1, ថ្ងៃទី ២០ ខែ មិថុនា ឆ្នាំ ២០១៦។

[14] សារណា, កថាខណ្ឌ ៥-១៤។

[15] ដើម្បីងាយយោងពីសំណាក់ភាគី និងអង្គជំនុំជម្រះសាលាដំបូង សហមេធាវីនាំមុខបង្ហាញបញ្ញត្តិខាងក្រោមពីតុលាការដទៃដែលធ្វើប្រតិបត្តិការក្នុងបរិបទឧក្រិដ្ឋកម្មអន្តរជាតិក្រោមក្របខណ្ឌគតិយុត្តិខុសៗគ្នាដែលប្រើប្រាស់វាក្យស័ព្ទនេះជំនួសវិញ។ សហមេធាវីនាំមុខស្នើសុំឲ្យមេធាវីការពារក្តី នួន ជា ប្រៀបធៀបបញ្ញត្តិទាំងនេះជាមួយវិធានផ្ទៃក្នុង ៨០៖
តុលាការឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់អតីតយូហ្គោស្លាវី វិធាន៦៥*ស្ទួនពីរ* "(ឆ) ក្រោយពេលបិទបញ្ចប់ការការពារខ្លួនរបស់រដ្ឋអាជ្ញា និងមុនពេលចាប់ផ្តើម<u>ការការពារខ្លួនរបស់មេធាវីការពារក្តី</u> ចៅក្រមបុរេជំនុំជម្រះត្រូវបង្គាប់ឲ្យមេធាវីការពារក្តីដាក់

ឯកសារ/សម្ភារដូចតទៅ (i) បញ្ជីសាក្សីដែលមេធាវីការពារក្តីមានបំណងកោះហៅ [...] (ii) បញ្ជីវត្ថុតាងដែលមេធាវីការពារក្តីមានបំណងផ្តល់ក្នុងការការពារខ្លួន ដោយបញ្ជាក់តាមដែលអាចធ្វើទៅបាន ថាតើរដ្ឋអាជ្ញាមានការជំទាស់ទៅនឹងយថាភាពដែរឬទេ។ មេធាវីការពារក្តីត្រូវប្រគល់ជូនរដ្ឋអាជ្ញានូវច្បាប់ថតចម្លងនៃវត្ថុដែលបានចុះបញ្ជី"។

តុលាការឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់រ្វ៉ាន់ដាមានបញ្ញត្តិស្រដៀងនេះ, វិធាន៧៣*ស្ទួនពីរ* "(ក) អង្គជំនុំជម្រះសាលាដំបូងអាចធ្វើសន្និសីទមួយមុនពេលចាប់ផ្តើមការការពារខ្លួនរបស់មេធាវីការពារក្តី (ខ)។ នៅក្នុងសន្និសីទនោះ អង្គជំនុំជម្រះសាលាដំបូង ឬចៅក្រមដែលទទួលបានការតែងតាំងពីក្នុងចំណោមសមាជិករបស់ខ្លួន អាចបង្គាប់ឱ្យមេធាវីការពារក្តី នៅមុនពេលចាប់ផ្តើមការការពារខ្លួន ប៉ុន្តែក្រោយពេលបិទបញ្ចប់ការការពារខ្លួនរបស់រដ្ឋអាជ្ញា ដាក់ឯកសារ/សម្ភារដូចតទៅ [....] (iv) បញ្ជីវត្ថុតាងដែលមេធាវីការពារក្តីមានបំណងផ្តល់ក្នុងការការពារខ្លួន ដោយបញ្ជាក់តាមដែលអាចធ្វើទៅបាន ថាតើរដ្ឋអាជ្ញាមានការជំទាស់អំពីយថាភាពដែរឬទេ។ អង្គជំនុំជម្រះសាលាដំបូង ឬចៅក្រម អាចបង្គាប់ឱ្យមេធាវីការពារក្តីផ្តល់ជូនអង្គជំនុំជម្រះសាលាដំបូងនូវច្បាប់ថតចម្លងនៃចម្លើយជាលាយលក្ខណ៍អក្សររបស់សាក្សីម្នាក់ៗដែលមេធាវីការពារក្តីមានបំណងកោះហៅមកផ្តល់សក្ខីកម្ម។ [...] (ង) បន្ទាប់ពីការចាប់ផ្តើមការការពារខ្លួនរបស់មេធាវីការពារក្តី មេធាវីការពារក្តីអាច ប្រសិនបើខ្លួនយល់ថាជាផលប្រយោជន៍នៃយុត្តិធម៌ ដាក់ញត្តិមួយដើម្បីបញ្ជាក់ជាថ្មីអំពីបញ្ជីឈ្មោះសាក្សី ឬកែប្រែការសម្រេចរបស់ខ្លួនអំពីសាក្សីណាខ្លះដែលត្រូវកោះហៅ។

តុលាការពិសេសសម្រាប់សៀរ៉ាឡេអូន, វិធាន ៧៣ស្ទួនពីរ "(ក) អង្គជំនុំជម្រះសាលាដំបូង ឬចៅក្រម ដែលបានការតែងតាំងពីសមាជិករបស់ខ្លួន អាចធ្វើសន្និសីទមុនពេលមេធាវីការពារក្តីធ្វើការការពារខ្លួន (ខ) មុនសន្និសីទនោះ អង្គជំនុំជម្រះសាលាដំបូង ឬចៅក្រមដែលបានការតែងតាំងពីសមាជិក អាចបង្គាប់ឱ្យមេធាវីការពារក្តី នៅពេលមុនចាប់ផ្តើមការការពារខ្លួន ប៉ុន្តែក្រោយបិទបញ្ចប់ការការពារខ្លួនរបស់រដ្ឋអាជ្ញា ដាក់ឯកសារ/សម្ភារដូចតទៅ [...] (iii) បញ្ជីសាក្សី ដែលមេធាវីការពារក្តីមានបំណងកោះហៅ [...] (iv) បញ្ជីវត្ថុតាងដែលមេធាវីការពារក្តីមានបំណងផ្តល់ក្នុងការការពារខ្លួន ដោយគូសបញ្ជាក់តាមដែលអាចធ្វើទៅបាន ថាតើរដ្ឋអាជ្ញាជំទាស់អំពីយថាភាពដែរឬទេ។ អង្គជំនុំជម្រះសាលាដំបូង ឬចៅក្រមនោះ អាចបង្គាប់ឱ្យមេធាវីការពារក្តីផ្តល់ជូនអង្គជំនុំជម្រះសាលាដំបូង និងរដ្ឋអាជ្ញា នូវច្បាប់ថតចម្លងនៃចម្លើយជាលាយលក្ខណ៍អក្សររបស់សាក្សីម្នាក់ៗដែលមេធាវីការពារក្តីមានបំណងកោះហៅមកផ្តល់សក្ខីកម្ម។ (ង) បន្ទាប់ពីចាប់ផ្តើមការការពារខ្លួនរបស់មេធាវីការពារក្តី មេធាវីការពារក្តីអាច ប្រសិនបើខ្លួនយល់ថាជាផលប្រយោជន៍នៃយុត្តិធម៌ ស្នើសុំអង្គជំនុំជម្រះសាលាដំបូងឱ្យផ្តល់ការអនុញ្ញាត ដើម្បីបញ្ជាក់ជាថ្មីអំពីបញ្ជីសាក្សី ឬកែប្រែការសម្រេចរបស់ខ្លួនអំពីថាសាក្សីណាខ្លះដែលត្រូវកោះហៅ"។

តុលាការពិសេសសម្រាប់លីបង់ វិធាន១១២៖ "(ក) នៅចុងបញ្ចប់នៃការការពារខ្លួនរបស់រដ្ឋអាជ្ញា បន្ទាប់ពីមានការជ្រើសរើសមេធាវីការពារក្តីដើម្បីបង្ហាញការការពារខ្លួន ក្នុងរយៈពេលកំណត់ដោយចៅក្រមអង្គបុរេជំនុំជម្រះ ឬអង្គជំនុំជម្រះសាលាដំបូង ប៉ុន្តែមិនតិចជាង១សប្តាហ៍មុនពេលមេធាវីការពារក្តីធ្វើការការពារខ្លួន មេធាវីការពារក្តីត្រូវ៖ [...] (ii) ផ្តល់ជូនរដ្ឋអាជ្ញានូវច្បាប់ថតចម្លងនៃចម្លើយទាំងអស់ដែលបានយកអនុលោមតាមវិធាន៩៣,១២៣,១២៥,១៥៥,១៥៦,១៥៧ និង១៥៨ ដែលមេធាវីការពារក្តីមានបំណងបង្ហាញនៅសវនាការ។ ច្បាប់ថតចម្លងនៃចម្លើយទាំងនេះរបស់សាក្សីបន្ថែម ប្រសិនបើមាន ត្រូវបង្ហាញទៅរដ្ឋអាជ្ញា មុនពេលមានសេចក្តីសម្រេចកោះហៅសាក្សីទាំងនោះ។ (គ) ការខកខានរបស់មេធាវីការពារក្តីមិនផ្តល់ការជូនដំណឹងអនុលោមតាវិធាននេះ នឹងមិនកំហិតសិទ្ធិរបស់មេធាវីការពារក្តីក្នុងការពឹងផ្អែកទៅលើការការពារខ្លួនខាងលើឡើយ។ (ឃ) អង្គជំនុំជម្រះសាលាដំបូងត្រូវចាត់ទុកការការពារក្តីដែលមាននៅពេលមានភស្តុតាងជាបញ្ហាផ្នែកច្បាប់ក្នុងកាលៈទេសៈអង្គហេតុពាក់ព័ន្ធ បើទោះជាការការពារខ្លួននោះពុំត្រូវបានលើកឡើងដោយមេធាវីការពារក្តីក៏ដោយ"។

ផ្តួចផ្តើមដោយដីកាសន្និដ្ឋានបញ្ជូនរឿងស៊ើបសួរតាមសំណើរបស់ព្រះរាជអាជ្ញា សហចៅក្រមស៊ើបអង្កេតជាអ្នកស៊ើបអង្កេតទៅលើអង្គហេតុដែលមានក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ ឬដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរបន្ថែម ដោយឥតលម្អៀង "ទោះជាវាជាភស្តុតាងដោះបន្ទុក ឬដាក់បន្ទុកក៏ដោយ"[16]។ សំណុំឯកសារនៅដំណាក់កាលមុនជំនុំជម្រះ ត្រូវបានបន្ថែមដោយទទ្បីករណ៍ និងសារណារបស់ភាគីទាំងអស់។ សហជនជាប់ចោទមានសិទ្ធិជំទាស់ទៅនឹង ការចោទប្រកាន់[17] សិទ្ធិធ្វើសំណើសុំឲ្យបំពេញកិច្ចស៊ើបសួរ[18] សិទ្ធិដាក់សេចក្តីកត់សម្គាល់ ដើម្បីបដិសេធ

---

[16] វិធានផ្ទៃក្នុង៥៥(៥)។

[17] វិធានផ្ទៃក្នុង៧៤(៣)៖ "៣. ជនត្រូវចោទ ឬជនជាប់ចោទ អាចធ្វើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកា ឬសេចក្តីសម្រេចរបស់សហចៅក្រមស៊ើបអង្កេតដូចខាងក្រោម៖ ក) ការបញ្ជាក់ពីយុត្តាធិការរបស់អង្គជំនុំជម្រះវិសាមញ្ញ ខ) ការបដិសេធពាក្យសុំឲ្យមានកិច្ចស៊ើបសួរណាមួយដែលអនុញ្ញាតក្រោមវិធានផ្ទៃក្នុង គ) ការបដិសេធពាក្យសុំឲ្យប្រគល់មកវិញនូវវត្ថុដែលចាប់យក ឃ) ការបដិសេធពាក្យសុំរបាយការណ៍របស់អ្នកជំនាញ ដែលអនុញ្ញាតក្រោមវិធានផ្ទៃក្នុង ង) ការបដិសេធពាក្យសុំធ្វើកិច្ចស៊ើបសួរបន្ថែមណាមួយដោយអ្នកជំនាញដែលអនុញ្ញាតក្រោមវិធាននេះ ច) ពាក់ព័ន្ធនឹងការឃុំខ្លួនបណ្តោះអាសន្ន ឬការត្រួតពិនិត្យតាមផ្លូវតុលាការ ឆ) ការបដិសេធពាក្យសុំឲ្យប្តឹងទៅអង្គបុរេជំនុំជម្រះដើម្បីមោឃភាពកិច្ចស៊ើបសួរណាមួយ ជ) ទាក់ទងទៅនឹងវិធានការការពារ ឈ) ការប្រកាសទទួលយកពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ឬ ញ) ការកាត់បន្ថយវិសាលភាពនៃកិច្ចស៊ើបសួររបស់តុលាការអនុលោមតាមវិធាន ៦៦ ស្ទួននៃវិធានផ្ទៃក្នុង"។

[18] វិធានផ្ទៃក្នុង៥៥(១០)៖ "១០. នៅគ្រប់ពេលវេលានៃការស៊ើបសួរ សហព្រះរាជអាជ្ញា ជនត្រូវចោទ ឬដើមបណ្តឹងរដ្ឋប្បវេណីអាចស្នើសុំឲ្យសហចៅក្រមស៊ើបអង្កេតចេញដីកា ឬបំពេញកិច្ចស៊ើបសួរណាមួយដែលខ្លួនយល់ឃើញថាមានប្រយោជន៍ដល់ការស៊ើបសួរ។ ប្រសិនបើសហចៅក្រមស៊ើបអង្កេតមិនយល់ព្រម សហចៅក្រមស៊ើបអង្កេតត្រូវចេញដីកាបដិសេធឲ្យបានឆាប់បំផុតតាមដែលអាចធ្វើទៅបាន ហើយនៅគ្រប់ករណីទាំងអស់ត្រូវចេញដីកានេះឲ្យបានមុនពេលបញ្ចប់កិច្ចស៊ើបសួរ។ ដីកាបដិសេធនេះត្រូវមានសំអាងហេតុ ហើយត្រូវជូនដំណឹងដល់ភាគី។ ដីកាបដិសេធនេះបើកផ្លូវប្តឹងឧទ្ធរណ៍។ *សូមមើលបន្ថែម* វិធានផ្ទៃក្នុង៦៦(១)៖ "នៅពេលដែលសហចៅក្រមស៊ើបអង្កេតយល់ឃើញថាការស៊ើបសួរត្រូវបានបញ្ចប់ សហចៅក្រមស៊ើបអង្កេតត្រូវជូនដំណឹងដល់គ្រប់ភាគី និងមេធាវីរបស់ភាគី។ សេចក្តីជូនដំណឹងអំពីការបិទកិច្ចស៊ើបសួរនេះត្រូវប្រកាសជាសាធារណៈ។ ភាគីទាំងអស់មានរយៈពេល១៥ថ្ងៃដើម្បីសុំឲ្យមានកិច្ចស៊ើបសួរបន្ថែម។ ភាគីទាំងអស់អាចលះបង់ថេរៈវេលានេះបាន"។ *សូមមើលបន្ថែម* វិធានផ្ទៃក្នុង៥៨(៦)៖ "ក្នុងអំឡុងពេលស៊ើបសួរ ជនត្រូវចោទអាចស្នើសុំឲ្យសហចៅក្រមស៊ើបអង្កេតសួរចម្លើយខ្លួន ស្តាប់ចម្លើយសាក្សី ចុះទៅដល់ទីកន្លែងកើតហេតុ បង្គាប់ឲ្យធ្វើកោសល្យវិច័យ ឬប្រមូលយកភស្តុតាងដទៃទៀត។ សំណើនេះត្រូវធ្វើជាលាយលក្ខណ៍អក្សរដោយមានបញ្ជាក់មូលហេតុពិតប្រាកដ។ ប្រសិនបើសហចៅក្រមស៊ើបអង្កេតមិនយល់ព្រមតាមសំណើនេះទេ សហចៅក្រមស៊ើបអង្កេតត្រូវចេញដីកាបដិសេធឲ្យបានឆាប់បំផុតតាមដែលអាចធ្វើទៅបាននិងនៅគ្រប់ករណីទាំងអស់ត្រូវចេញដីកាបដិសេធនេះនៅមុនពេលបញ្ចប់កិច្ចស៊ើបសួរ។ ដីកាបដិសេធត្រូវមានសំអាងហេតុ។ ជនត្រូវចោទត្រូវបានជូនដំណឹងជាបន្ទាន់អំពីដីកាបដិសេធនេះ។ ជនត្រូវចោទអាចធ្វើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកានេះទៅអង្គបុរេជំនុំជម្រះ"។ *សូមមើលផងដែរ* ក្រមនីតិវិធីព្រហ្មទណ្ឌ២០០៨ មាត្រា១៣៣។

មុនពេលបិទបញ្ចប់កិច្ចស៊ើបសួរ[19] សិទ្ធិប្តឹងឧទ្ធរណ៍ចំពោះរាល់ការចោទប្រកាន់ផ្នែកអង្គហេតុក្នុងដីកាដំណោះស្រាយ[20] សិទ្ធិប្តឹងឧទ្ធរណ៍ជំទាស់ដីកាដំណោះស្រាយដោយផ្អែកលើកំហុសនីតិវិធី[21] សិទ្ធិធ្វើអញ្ញត្រកម្មមុនពេលចាប់ផ្តើមការជំនុំជម្រះ[22] សិទ្ធិដាក់បញ្ជីសាក្សី អ្នកជំនាញ និងដើម

[19] វិធានផ្ទៃក្នុង៧៦(៦)៖“ភាគីណាមួយដែលផលប្រយោជន៍របស់ខ្លួនត្រូវបានប៉ះពាល់ដោយកិច្ចស៊ើបសួរដែលគ្មានសុពលភាពអាចលះបង់សិទ្ធិស្នើសុំមោឃភាពបាន។ ការធ្វើដូចនេះផ្តល់និយតភាពដល់កិច្ចដំណើរការនីតិវិធី។ សហចៅក្រមស៊ើបអង្កេតត្រូវដាក់ពាក្យលះបង់សិទ្ធិបែបនេះទៅក្នុងសំណុំរឿង។នៅពេលដែលភាគីដែលស្នើសុំនោះមានមេធាវី សហចៅក្រមស៊ើបអង្កេតត្រូវ កោះហៅមេធាវីនោះយ៉ាងហោចណាស់ប្រាំថ្ងៃមុនថ្ងៃកត់ត្រាទុកពាក្យលះបង់សិទ្ធិនេះដើម្បីឱ្យមេធាវីអាចពិនិត្យសំណុំរឿងបាន”។ *សូមមើលបន្ថែម* វិធានផ្ទៃក្នុង៦៧(៣)(គ)៖ “សហចៅក្រមស៊ើបអង្កេតត្រូវចេញដីកាលើកលែងចោទប្រកាន់ក្នុងករណីដូចខាងក្រោម [...] ពុំមានភស្តុតាងគ្រប់គ្រាន់ដើម្បីផ្តន្ទាទោសជនត្រូវចោទ”។ *សូមមើលផង* ក្រមនីតិវិធីព្រហ្មទណ្ឌ២០០៨, មាត្រា ២៤៧។

[20] វិធានផ្ទៃក្នុង៦៦(៣)៖ “ក្នុងរយៈពេល៣០ថ្ងៃ ក្រោយពីបានទទួលដំណឹងអំពីដីកាសម្រេចនេះភាគីទាំងអស់អាចប្តឹងឧទ្ធរណ៍ ទៅអង្គបុរេជំនុំជម្រះ។ ភាគីទាំងអស់អាចបោះបង់ចោលសិទ្ធិប្តឹងឧទ្ធរណ៍នេះបាន ទោះបីជាមានវត្តមានរបស់មេធាវី ឬក្នុងករណីដែលមេធាវីត្រូវបានកោះហៅដោយត្រឹមត្រូវប៉ុន្តែមិនបានចូលបង្ហាញខ្លួន”។

[21] វិធានផ្ទៃក្នុង៧៦(២)៖ “ក្នុងអំឡុងពេលនៃកិច្ចស៊ើបសួរ នៅពេលដែលភាគីទាំងឡាយយល់ឃើញថាមានផ្នែកណាមួយត្រូវបានចាត់ទុកជាមោឃៈ ភាគីនោះអាចដាក់ពាក្យសុំដោយបញ្ជាក់មូលហេតុទៅសហចៅក្រមស៊ើបអង្កេតដើម្បីស្នើសុំឱ្យសហចៅក្រមស៊ើបអង្កេតប្តឹងទៅអង្គបុរេជំនុំជម្រះស្នើសុំឱ្យធ្វើមោឃភាព។ សហចៅក្រមស៊ើបអង្កេតត្រូវចេញដីកាដែលអាចជាការទទួលយក ឬបដិសេធសំណើសុំភ្លាមៗតាមតែអាចធ្វើទៅបាន និងក្នុងគ្រប់ករណីទាំងអស់ត្រូវធ្វើឡើងមុនពេលចេញដីកាដំណោះស្រាយ។ ដីកាបែបនេះគឺជាកម្មវត្ថុនៃបណ្តឹងឧទ្ធរណ៍ ដោយអនុលោមតាមវិធានផ្ទៃក្នុងនេះ។ “*សូមមើលផង* វិធានផ្ទៃក្នុង៧៤(៣)៖ “៣. ជនត្រូវចោទ ឬជនជាប់ចោទអាចធ្វើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកា ឬសេចក្តីសម្រេចរបស់សហចៅក្រមស៊ើបអង្កេតដូចខាងក្រោម៖

ក- ការបញ្ជាក់ពីយុត្តាធិការរបស់អង្គជំនុំជម្រះវិសាមញ្ញ ខ- ការបដិសេធពាក្យសុំឱ្យមានកិច្ចស៊ើបសួរណាមួយដែលអនុញ្ញាតក្រោមវិធានផ្ទៃក្នុង គ- ការបដិសេធពាក្យសុំឱ្យប្រគល់មកវិញនូវវត្ថុដែលចាប់យក ឃ-ការបដិសេធពាក្យសុំរបាយការណ៍របស់អ្នកជំនាញដែលអនុញ្ញាតក្រោមវិធានផ្ទៃក្នុង ង-ការបដិសេធពាក្យសុំធ្វើកិច្ចស៊ើបសួរបន្ថែមណាមួយដោយអ្នកជំនាញដែលអនុញ្ញាតក្រោមវិធាននេះ ច-ពាក់ព័ន្ធនឹងការឃុំខ្លួនបណ្តោះអាសន្ន ឬការត្រួតពិនិត្យតាមផ្លូវតុលាការ ឆ-ការបដិសេធពាក្យសុំឱ្យ ប្តឹងទៅអង្គបុរេជំនុំជម្រះដើម្បីមោឃភាពកិច្ចស៊ើបសួរណាមួយ ជ-ទាក់ទងវិធានការការពារ ឈ- ការប្រកាសទទួលយកពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ឬ ញ-ការកាត់បន្ថយវិសាលភាពនៃកិច្ចស៊ើបសួររបស់តុលាការអនុលោមតាមវិធាន ៦៦ ស្ទួននៃវិធានផ្ទៃក្នុង”។ *សូមមើលផង* ក្រមនីតិវិធីព្រហ្មទណ្ឌ២០០៨ មាត្រា២៥៣។

[22] វិធានផ្ទៃក្នុង ៨៩៖ “អញ្ញត្រកម្មទាក់ទងទៅនឹង៖ ក)យុត្តាធិការរបស់អង្គជំនុំជម្រះសាលាដំបូង ខ) ការរលត់បណ្តឹងអាជ្ញា គ)មោឃភាពនីតិវិធីត្រូវបានធ្វើបន្ទាប់ពីមានដីកាដំណោះស្រាយ ត្រូវលើកឡើងយ៉ាងយូរ ៣០ ថ្ងៃ ក្រោយពីដីកាដំណោះស្រាយចូលជាស្ថាពរ បើមិនដូច្នេះទេអញ្ញត្រកម្មនោះមិនអាចត្រូវបានទទួលយកឡើយ”។

បណ្តឹងរដ្ឋប្បវេណី ដែលត្រូវបានស្នើសុំឱ្យកោះហៅឱ្យមកផ្តល់សក្ខីកម្មក្នុងអំឡុងពេលសវនាការ[23] ក្នុងចំណោមសិទ្ធិផ្សេងៗទៀត។ បញ្ហាសំខាន់នៃច្បាប់ជាធរមាន និងគោលការណ៍នីត្យានុកូលភាព ដែលកថាខណ្ឌ ២៣,២៨-២៩ នៃសារណានេះលើកឡើង តាមពិតត្រូវបានពិភាក្សាយ៉ាងច្រើននៅដំណាក់កាលមុនជំនុំជម្រះ ហើយនិយមន័យ និងការចោទប្រកាន់អំពីបទឧក្រិដ្ឋសំខាន់ៗដូចដែលមានក្នុងដីកាដំណោះស្រាយ គឺជាលទ្ធផលនៃការជជែកដេញដោលនេះ។

11. មេធាវីការពារក្តី នួន ជា បានអនុវត្តសិទ្ធិខ្លះ ក្នុងចំណោមសិទ្ធិទាំងនោះ[24] ប៉ុន្តែ ពុំបានអនុវត្តចំពោះសាក្សីនានាដែលបានលើកឡើងក្នុងសំណើទីមួយឡើយ។ សហមេធាវីនាំមុខបន្ថែមថា មេធាវីការពារក្តី នួន ជា បានដឹងអំពីអត្ថិភាពនៃសាក្សីទាំងនោះ តាំងពីពេលមានដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរមកម្លេះ[25]។ ឧទាហរណ៍ ចម្លើយនៅ DC-Cam របស់សាក្សី 2-TCW-1033

---

[23] វិធានផ្ទៃក្នុង៨០(២)៖ "នៅពេលដែលជនជាប់ចោទ និង/ឬក្រុមរួមគ្នានៃដើមបណ្តឹងរដ្ឋប្បវេណី មានបំណងកោះហៅសាក្សីណាម្នាក់ដែលមិនមានឈ្មោះក្នុងបញ្ជីដែលផ្តល់ឱ្យដោយសហព្រះរាជអាជ្ញា ជនជាប់ចោទ និង/ឬដើមបណ្តឹងរដ្ឋប្បវេណី ត្រូវដាក់ជូនបញ្ជីឈ្មោះបន្ថែម រួមទាំងការបញ្ជាក់នូវទំនាក់ទំនងញាតិដែលមានចែងក្នុងវិធាន២៤(២) ដល់ក្រឡាបញ្ជីរបស់អង្គជំនុំជម្រះសាលាដំបូងក្នុងរយៈពេល១៥ថ្ងៃគិតចាប់ពីថ្ងៃទទួលដំណឹងនៃបញ្ជីឈ្មោះសាក្សី។ ក្រឡាបញ្ជីត្រូវដាក់បញ្ជីនេះទៅក្នុងសំណុំរឿង និងបញ្ជូនបញ្ជីឈ្មោះថតចម្លងទៅឱ្យភាគីដទៃទៀតដោយគោរពទៅតាមវិធានការការពារ"។

[24] *សូមមើល ឧទាហរណ៍* សំណើទី២១ សុំបំពេញកិច្ចស៊ើបសួរ, ឯកសារ D320, ថ្ងៃទី ១៥ ខែ មករា ឆ្នាំ ២០១០, កថាខណ្ឌ ១៧ ដែលស្នើសុំសហចៅក្រមស៊ើបអង្កេត *ក្នុងចំណោមប្រការផ្សេងៗ* ស្តាប់ចម្លើយឡើងវិញនូវសាក្សី ឡុង នរិន្ទ និងសួរសំណួរមួយចំនួនដែលភ្ជាប់ទៅនឹងសំណើនោះ។ *សូមមើលបន្ថែម* សំណើទី២១ សុំបំពេញកិច្ចស៊ើបសួរ, ឯកសារ D320.1, ថ្ងៃទី ១៥ ខែ មករា ឆ្នាំ ២០១០ ដែលជាឧបសម្ព័ន្ធទៅនឹងឯកសារ D320 ដែលមានបញ្ជីសំណួរដែលមេធាវីការពារក្តី នួន ជា បានស្នើសុំឱ្យ ក.ស.ច.ស ស្តាប់ចម្លើយ ឡុង នរិន្ទ ឡើងវិញ។ សំណើនេះត្រូវបានឯកភាពដោយសហចៅក្រមស៊ើបអង្កេត, *សូមមើល* ដីកាសម្រេចស្តីពីសំណើរបស់ នួន ជា សុំស្តាប់ចម្លើយសាក្សី (D138, D139, D320, D336, D338, D339 និង D340), ឯកសារ D375, ថ្ងៃទី ៩ ខែ មេសា ឆ្នាំ ២០១០, កថាខណ្ឌ ២៣-២៤។ ក.ស.ច.ស បានឯកភាពសំណើនេះដូចដែលបានលើកក្នុងឯកសារ D320។ ផ្នែកសម្រេចសេចក្តីលើទំព័រ ១៤។ *សូមមើល* អញ្ញត្រកម្មរួមបញ្ចូលគ្នា, ឯកសារ E51/3, ថ្ងៃទី ២៥ ខែ កុម្ភៈ ឆ្នាំ ២០១១ ដែលសហជនជាប់ចោទបានស្នើសុំកិច្ចស៊ើបសួរមួយចំនួនដែលធ្លាប់ត្រូវបានបដិសេធទាំងស្រុង ឬមួយផ្នែកដោយសហចៅក្រមស៊ើបអង្កេត។ *សូមមើលផង* សេចក្តីសន្និដ្ឋានបឋមពាក់ព័ន្ធនឹងច្បាប់ជាធរមាន, ឯកសារ E163/5/11, ថ្ងៃទី ១៨ ខែ មករា ឆ្នាំ ២០១៣។ *សូមមើលបន្ថែម* សេចក្តីជូនដំណឹងស្តីពីការចូលរួមជាមួយសំណើលេខ E234 របស់ អៀង សារី, ឯកសារ E234/2, ខែ វិច្ឆិកា ឆ្នាំ ២០១២។

[25] 2-TCW-1032 (IS 19.219) កត់សម្គាល់ថា គាត់ត្រូវបានស្នើសុំស្តាប់ចម្លើយដោយមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី។ *សូមមើល* សំណើសុំកិច្ចស៊ើបអង្កេតរបស់សហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីទាក់ទងនឹងបទល្មើសនៃការបាត់ខ្លួនមនុស្សដោយបង្ខំ, ឯកសារ D180, ថ្ងៃទី ៣០ ខែ មិថុនា ឆ្នាំ ២០០៩។ សូមមើលបន្ថែម, 2-TCW-1031 (IS 19.175), 2-TCW-1030 (IS 19.201), 2-TCW-1029 (IS 19.193)។

ត្រូវបានលើកឡើងក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ[26] និងដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរបន្ថែមរបស់សហព្រះរាជអាជ្ញា ទាក់ទងមន្ទីរសន្តិសុខភូមិភាគឧត្តរ[27]។ ចម្លើយនៅ DC-Cam របស់គាត់ ក៏ត្រូវបានលើកឡើងក្នុងសំណើរបស់សហព្រះរាជអាជ្ញាសុំឲ្យបំពេញកិច្ចស៊ើបសួរ ទាក់ទងនឹងការដ្ឋានព្រលានយន្តហោះកំពង់ឆ្នាំង[28]។ សាក្សីនេះត្រូវបានស្ដាប់ចម្លើយដោយសហចៅក្រមស៊ើបអង្កេត[29] និងត្រូវបានលើកឡើងក្នុងរបាយការណ៍កំណត់អត្តសញ្ញាណទីកន្លែងសម្រាប់ព្រលានយន្តហោះកំពង់ឆ្នាំង[30]។ ភស្តុតាងរបស់សាក្សីនេះក៏ត្រូវបានលើកឡើងក្នុងដីកាដំណោះស្រាយដែរ[31]។ ប៉ុន្តែ មេធាវីការពារក្ដី នួន ជា ពុំបានអនុវត្តសិទ្ធិណាមួយក្នុងចំណោមសិទ្ធិទាំងឡាយដែលពួកគាត់មានទាក់ទងសាក្សីរូបនេះឡើយ ទាំងក្នុងដំណាក់កាលមុនជំនុំជម្រះ និងដំណាក់កាលជំនុំជម្រះមកទល់បច្ចុប្បន្ន។ ករណីនេះក៏ដូចគ្នាចំពោះសាក្សី 2-TCW-1029, 2-TCW-1030, 2-TCW-1031, 2TCW-1032 ដែរ។

12. មេធាវីការពារក្ដី នួន ជា ពុំបានប្ដឹងឧទ្ធរណ៍ជំទាស់ទៅនឹងដីកាដំណោះស្រាយផ្អែកលើកំហុសនីតិវិធីឡើយ។ ពួកគាត់ពុំបានប្ដឹងឧទ្ធរណ៍ដោយមូលហេតុថាពុំមានភស្តុតាងគ្រប់គ្រាន់ដាក់បន្ទុក នួន ជា[32] ឡើយ។ សហមេធាវីនាំមុខសូមបញ្ជាក់ថា ភាគីអាចជ្រើសរើសមិនប្ដឹងឧទ្ធរណ៍ជំទាស់

---

[26] *សូមមើល* IS 19.73។

[27] សេចក្ដីសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរបន្ថែមរបស់សហព្រះរាជអាជ្ញាពាក់ព័ន្ធមន្ទីរសន្តិសុខភូមិភាគឧត្តរ ឯកសារ D83, ថ្ងៃទី ២៦ ខែ មីនា ឆ្នាំ ២០០៨ កថាខណ្ឌ ២០។

[28] សំណើរបស់សហព្រះរាជអាជ្ញាសុំឲ្យបំពេញកិច្ចស៊ើបសួរទាក់ទងនឹងទីតាំងការដ្ឋានស្ថាបនាព្រលានយន្តហោះកំពង់ឆ្នាំង, ឯកសារ D245, ថ្ងៃទី ១៩ ខែ វិច្ឆិកា ឆ្នាំ ២០០៩។

[29] កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី ខឹម សំហួន, ឯកសារ D166/117, ថ្ងៃទី ៦ ខែ មីនា ឆ្នាំ ២០០៩។

[30] របាយការណ៍ស្ដីពីការកំណត់អត្តសញ្ញាណទីកន្លែង, ឯកសារ D232/100, ថ្ងៃទី ២ ខែ មករា ឆ្នាំ ២០១០។

[31] *សូមមើល ឧទាហរណ៍* ដីកាដំណោះស្រាយ, ជើងទំព័រ ៤២៩ (កថាខណ្ឌ ១៤១) ៤៥០ (កថាខណ្ឌ ១៤៨), ៦៩៥ (កថាខណ្ឌ ២០១) ៧១២ (កថាខណ្ឌ ២០៩) ៧៩៨ (កថាខណ្ឌ ២២៤) ៨៦៥ (កថាខណ្ឌ ២៣៥) ១៦៦៣ (កថាខណ្ឌ ៣៨៤) ១៦៧០ (កថាខណ្ឌ ៣៨៦) ១៦៨៥ (កថាខណ្ឌ ៣៨៨) ១៦៨៦, ១៦៨៧, ១៦៨៩ (កថាខណ្ឌ ៣៨៩) ១៦៩៧ (កថាខណ្ឌ ៣៨៩) ១៧០០ (កថាខណ្ឌ ៣៩០) ១៧០២ (កថាខណ្ឌ ៣៩០) ១៧០៥, ១៧១០,១៧១៥, ១៧១៦ (កថាខណ្ឌ ៣៩២), ១៧១៩, ១៧២០ (កថាខណ្ឌ ៣៩៣), ១៧២២, ១៧២៥ (កថាខណ្ឌ ៣៩៥), ១៧៣០ (កថាខណ្ឌ ៣៩៦) ១៧៣៩,១៧៤០,១៧៤១ (កថាខណ្ឌ ៣៩៨) ៤២១២ (កថាខណ្ឌ ១០១៧), ៤៧៣២ (កថាខណ្ឌ ១១៥២) ៤៧៨១ (កថាខណ្ឌ ១១៦៩)..

[32] បណ្ដឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ, ឯកសារ D427/3/1, ថ្ងៃទី ១៨ ខែ តុលា ឆ្នាំ ២០១០, កថាខណ្ឌ ៣៨៖ "ដូចមានហេតុផលលើកឡើងខាងលើ ក្រុមមេធាវីការពារក្ដីសូមសន្និដ្ឋានថា ក.ស.ច.ស មានការភ័ន្តច្រឡំលើអង្គច្បាប់នៅពេលបញ្ជាក់ថា អ.វ.ត.ក មានយុត្តាធិការលើបទប្រល័យពូជសាសន៍ បទឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ បទឧក្រិដ្ឋកម្មសង្គ្រាម និង

ទៅនឹងដីកាដំណោះស្រាយដោយផ្អែកលើកំហុសនីតិវិធី ប៉ុន្តែពេលនោះ ពួកគាត់ត្រូវបានហាមឃាត់មិនឱ្យលើកបញ្ហាទាំងនេះក្នុងអំឡុងសវនាការឡើយ។ កំហុសនីតិវិធី ប្រសិនបើមាន (ត្រូវបានជំទាស់ ឬអត់) ត្រូវបានចាត់ទុកថាត្រូវបានកែតម្រូវរួចហើយ និងមិនអនុញ្ញាតឱ្យលើកក្នុងអំឡុងដំណាក់កាលសវនាការឡើយ[33]។

13. សហមេធាវីនាំមុខបន្ថែមទៀតថា សិទ្ធិដែលផ្តល់ទៅឱ្យមេធាវីការពារក្តីនៅដំណាក់កាលមុនការជំនុំជម្រះ មានន័យថា ដីកាដំណោះស្រាយ និងការចោទប្រកាន់លើអង្គហេតុ គឺជាលទ្ធផលនៃការជជែកដេញដោលរវាងភាគី។

14. ក្របខណ្ឌគតិយុត្តិជាធរមាននៅ អ.វ.ត.ក អនុញ្ញាតឱ្យមានការការពារក្តី*មួយ* ក្នុងដីកាដំណោះស្រាយ ការចោទប្រកាន់លើអង្គហេតុដែលត្រូវតែបង្ហាញដោយរដ្ឋអាជ្ញា ដោយផ្អែកលើភស្តុតាងដែលមានក្នុងសំណុំរឿង *និង* ដែលត្រូវបានដាក់ចំពោះមុខអង្គជំនុំជម្រះ។

15. នៅពេលបញ្ជូនដីកាដំណោះស្រាយទៅជំនុំជម្រះ អង្គជំនុំជម្រះសាលាដំបូងបានទទួលចាត់ការ *(saisine)* លើការចោទប្រកាន់លើអង្គហេតុទាំងនោះ *(in rem)*[34] និងជាប់កាតព្វកិច្ចក្នុងការពិនិត្យ

---

ទម្រង់នៃការទទួលខុសត្រូវដទៃទៀត ដែលមិនមានចែងទទួលស្គាល់នៅក្នុងប្រព័ន្ធច្បាប់ជាតិកម្ពុជានៅចន្លោះពីឆ្នាំ ១៩៧៥ និងឆ្នាំ ១៩៧៩។ អាស្រ័យហេតុនេះ ក្រុមមេធាវីការពារក្តីសូមស្នើឱ្យ អ.ប.ជ ចាត់ទុកជាឥតបានការ និង/ឬកែតម្រូវដីកាដំណោះស្រាយឱ្យបានត្រឹមកម្រិតមួយថាការទទួលខុសត្រូវរបស់ នួន ជា ដូចដែលបានចោទប្រកាន់ ត្រូវបញ្ជាក់យោង ដាច់ដោយឡែកលើបទល្មើស និងទម្រង់នៃការទទួលខុសត្រូវនៅក្នុងច្បាប់សារធាតុដូចមានចែងនៅក្នុងក្រមព្រហ្មទណ្ឌឆ្នាំ ១៩៥៦។ យើងខ្ញុំសូមស្នើឱ្យមានសវនាការផ្ទាល់មាត់ជាសាធារណៈមួយដើម្បីជាផលប្រយោជន៍យុត្តិធម៌ និងតម្លាភាព។

[33] វិធាន ៧៦(៧)៖“លើកលែងតែជាកម្មវត្ថុនៃបណ្តឹងឧទ្ធរណ៍ ដីកាដំណោះស្រាយត្រូវកែតម្រូវកំហុសនៃការមិនគោរពវិធានបញ្ញត្តិក្នុងការស៊ើបសួរ។ គ្មានបញ្ហាណាមួយដែលពាក់ព័ន្ធនឹងកំហុសនីតិវិធីបែបនេះ អាចត្រូវបានលើកឡើងនៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង ឬអង្គជំនុំជម្រះតុលាការកំពូលឡើយ”។ សូមមើលបន្ថែម សេចក្តីសម្រេចលើអញ្ញត្រកម្មរបស់មេធាវីការពារក្តី ទាក់ទងនឹងយុត្តាធិការទៅលើការនិរទេសដែលជាឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ, ឯកសារ E306/5, ថ្ងៃទី ២៩ ខែ កញ្ញា ឆ្នាំ ២០១៤ កថាខណ្ឌ ៩ “ខៀវ សំផន មានឱកាសរកឃើញភាពមិនប្រក្រតីដែលជាបញ្ហានៅពេលនេះ។ ប្រសិនបើវិសាលភាពនៃកិច្ចស៊ើបសួរគឺជាបញ្ហានៃភាពចម្រូងចម្រាស បញ្ហានេះគួរតែត្រូវបានលើកឡើងនៅមុនពេលបើកសវនាការ។ យោងតាមវិធាន ៧៦(៧)នៃវិធានផ្ទៃក្នុង អង្គជំនុំជម្រះបានទទួលដីកាដំណោះស្រាយដែលត្រូវបានកែតម្រូវកំហុសនៃការមិនគោរពវិធានបញ្ញត្តិក្នុងការស៊ើបសួរ”។

[34] សម្រាប់និយមន័យនៃពាក្យ *saisine in rem,* សូមមើល សំណុំរឿង ០០៣, សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ [កោសលប់] ប្រឆាំងនឹងដីកាសហចៅក្រមស៊ើបអង្កេត Harmon ដែលសម្រេចលើពាក្យសុំរបស់ [កោសលប់]ស្នើឱ្យអង្គបុរេជំនុំជម្រះ

ទៅលើការចោទប្រកាន់ទាំងនោះតាមរយៈការដាក់ការចោទប្រកាន់ទាំងនេះទៅក្នុងវគ្គទីពីរនៃការជជែកដេញដោលដោយគោរពគោលការណ៍ចំពោះមុខ។ ទោះជាបន្ទុកនៃការបង្ហាញភស្តុតាងលើការចោទប្រកាន់លើអង្គហេតុទាំងនេះ ស្ថិតនៅលើរដ្ឋអាជ្ញាក៏ដោយ ក៏ការទទួលចាត់ការ *(Saisine)* នេះមិនចំណុះឲ្យ "សំណុំរឿងរដ្ឋអាជ្ញា" ឬ "សំណុំរឿងមេធាវីការពារក្តីឡើយ"។

16. ចៅក្រមនៃអង្គជំនុំជម្រះសាលាដំបូងដែលសម្រេចទៅលើការចោទប្រកាន់លើអង្គហេតុទាំងនោះ អាចចូលពិនិត្យភស្តុតាងនេះ និងសំណុំរឿងទាំងមូល[35] នៅពេលដែលការិយាល័យសហចៅក្រមស៊ើបអង្កេតជូនដំណឹងទៅអង្គជំនុំជម្រះសាលាដំបូង[36] និងជាបន្តបន្ទាប់ នៅពេលភាគីនានាដាក់ឯកសារទៅក្នុងសំណុំរឿងនេះ[37]។

17. សហមេធាវីនាំមុខអះអាងថា មិនដូចនីតិវិធីច្បាប់ common law ការជំនុំជម្រះពុំពឹងផ្អែកលើភស្តុតាងដែលដាក់បន្ថែមដោយភាគី និងសារណានៃ*ការការពារក្តី*នីមួយៗរបស់ភាគី ដោយផ្អែកកាន់តែតិចតួចទៅលើភស្តុតាងរបស់មេធាវីការពារក្តី (ឬដើមបណ្តឹងរដ្ឋប្បវេណី)[38]។ នេះពុំមានន័យថាជនជាប់ចោទក្រោមក្របខណ្ឌគតិយុត្តិទាំងនេះ ត្រូវបានរារាំងមិនឲ្យធ្វើការការពារខ្លួនឡើយ។ អ្វីដែលវាសន្និដ្ឋាននោះគឺថា ការជំនុំជម្រះរឿងក្តីព្រហ្មទណ្ឌ ក្នុងក្របខណ្ឌទាំងនេះ ពុំមែនជាការជំទាស់តវ៉ារវាង*សំណុំរឿងផ្សេងៗ*ឡើយ ប៉ុន្តែជាដំណើរការមួយ ក្នុងការអនុញ្ញាតឲ្យមានការបញ្ជាក់ការពិតទាក់ទងអង្គហេតុផ្សេងៗពាក់ព័ន្ធពិរុទ្ធភាព ឬការគ្មានពិរុទ្ធភាពរបស់ជនជាប់ចោទដែលមាននៅក្នុងដីកាដំណោះស្រាយ[39]។

---

ទទួលពិនិត្យ និងចាត់ការលើសំណើចំនួនពីរសុំមោឃភាពកិច្ចស៊ើបសួរ, ឯកសារ D134/1/10, ថ្ងៃទី ២៣ ខែ ធ្នូ ឆ្នាំ ២០១៥, យោបល់ចៅក្រមអន្តរជាតិលើសំណើសុំធ្វើមោឃភាពកិច្ចស៊ើបសួរពាក់ព័ន្ធនឹង [កោសលប់] កថាខណ្ឌ ៧-៩។

[35] *សូមមើល* វិធានផ្ទៃក្នុង៦៩(២)(ក)៖ "ប្រសិនបើមានដីកាបញ្ជូនរឿងទៅជំនុំជម្រះ ក្រឡាបញ្ជីរបស់សហចៅក្រមស៊ើបអង្កេតត្រូវបញ្ជូនសំណុំរឿងទៅក្រឡាបញ្ជីរបស់អង្គជំនុំជម្រះសាលាដំបូងដើម្បីកំណត់កាលបរិច្ឆេទសវនាការ"។

[36] វិធានផ្ទៃក្នុង៧៩(១)។

[37] វិធានផ្ទៃក្នុង៨០,៨៧(៤)។

[38] ប្រៀបធៀបវិធាន៦៥ស្ទួនពីរ នៃតុលាការ ICTY ដែលភាគីត្រូវបានរំពឹងថាដាក់បញ្ជីភស្តុតាង*ក្រោយ*ការបង្ហាញការការពារខ្លួនរបស់រដ្ឋអាជ្ញា។ ការបង្ហាញភស្តុតាងមុខអង្គជំនុំជម្រះសាលាដំបូងអាស្រ័យលើការទទួលយកជាភស្តុតាងនូវឯកសារទាំងនោះ *តាមរយៈ* សាក្សី។

[39] អង្គជំនុំជម្រះសាលាដំបូងបានទទួលការជូនដំណឹងពីការចោទប្រកាន់លើអង្គហេតុ និងការកំណត់បទចោទសក្តានុពលដែលមានក្នុងដីកាដំណោះស្រាយ។ ខ្លួនពុំបានកំពុងសម្រេចលើការចោទប្រកាន់ដែលរៀបចំដោយរដ្ឋអាជ្ញាឡើយ ដែលជាមូលដ្ឋាននៃ "ការការពារខ្លួនរបស់រដ្ឋអាជ្ញា" ក្នុងយុត្តាធិការច្បាប់ common law។

18. ត្រង់កថាខណ្ឌ ១៥ សារណានេះលើកឡើងថា៖ “ការដាក់បុរេលក្ខខណ្ឌបែបនេះលើព័ត៌មានដែលមេធាវីការពារក្តីបានផ្តល់រួចហើយទាក់ទងនឹងសាក្សីនោះ គឺជាការរំលោភបំពានយ៉ាងច្បាស់ក្រឡែតទៅលើសិទ្ធិរបស់ នួន ជា ក្នុងការទទួលបានការជំនុំជម្រះដោយយុត្តិធម៌”[40]។ សហមេធាវីនាំមុខសូមអះអាងថា ការចោទប្រកាន់អំពីការរំលោភសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌របស់ជនជាប់ចោទ ត្រូវតែវាយតម្លៃក្នុងបរិបទនៃក្របខណ្ឌគតិយុត្តិនៃការជំនុំជម្រះសំណុំរឿងព្រហ្មទណ្ឌនេះ។ ការយល់ច្រឡំដែលៗអំពីក្របខណ្ឌជាធរមាន និង/ឬ ការអំណះអំណាងអំពីក្របខណ្ឌស្របគ្នាមួយដែលពុំមែនជាផ្នែកមួយនៃច្បាប់កម្ពុជា ឬក្របខណ្ឌគតិយុត្តិ អ.វ.ត.ក ពុំអាចត្រូវបានចាត់ទុកជាមូលដ្ឋាននៃការរំលោភសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌ឡើយ។

**(ខ) ចម្លើយតបលើការបំពេញតាមសេចក្តីបង្គាប់របស់អង្គជំនុំជម្រះសាលាដំបូង**

19. សហមេធាវីនាំមុខសូមអះអាងថា ភាគីមានសិទ្ធិដាក់បន្ថែមភស្តុតាងទៅក្នុងសំណុំរឿង ដើម្បីបង្ហាញអំពីផ្នែកផ្សេងៗនៃការពិតក្នុងអំឡុងពេលសវនាការ និងការបកស្រាយដែលអាចមានអំពីភស្តុតាងនេះក្នុងសារណាស្តាពររបស់ពួកគាត់។ ប៉ុន្តែ ភស្តុតាងទាំងអស់នេះក្នុងអំឡុងពេលជំនុំជម្រះ ត្រូវតែទាក់ទងទៅនឹងការចោទប្រកាន់លើអង្គហេតុដែលមានក្នុងដីកាដំណោះស្រាយ[41]។

20. កាតព្វកិច្ចក្នុងការភ្ជាប់ទំនាក់ទំនងរវាងភស្តុតាង និងការចោទប្រកាន់លើអង្គហេតុ ត្រូវអនុវត្តដូចគ្នាចំពោះភាគី *ទាំងអស់*[42]។ ការអនុវត្តកាតព្វកិច្ចនេះអាចធ្វើទៅបាននៅគ្រប់ដំណាក់កាលនៃកិច្ចដំណើរការនិតិវិធីដែលពាក់ព័ន្ធទាំងអស់។ ការដែលមិនមានលក្ខខណ្ឌតម្រូវនេះ នៅពេលស្នើសុំភស្តុតាង “ថ្មី” អនុលោមតាមវិធានផ្ទៃក្នុង៨៧(៤) ដែលជាលក្ខខណ្ឌតឹងជាង គឺជាការដកលក្ខខណ្ឌតម្រូវក្នុងវិធានផ្ទៃក្នុង ៨០(៣) ដែលជាការរំលោភទៅលើគោលបំណងរបស់ការដាក់លក្ខខណ្ឌនេះ។

---

[40] *សូមមើលផង* សារណា កថាខណ្ឌ ៤៣-៤៦។

[41] វិធានផ្ទៃក្នុង៨០។

[42] វិធានផ្ទៃក្នុង៨០(៣)(ក)៖ “បន្ថែមទៅនឹងបញ្ជីឈ្មោះសាក្សីដែលមានយោងក្នុងវិធាន៨០នៃវិធានផ្ទៃក្នុង៖ (i) សេចក្តីសង្ខេបអង្គហេតុដែលសាក្សីគ្រប់រូបរំពឹងថានឹងធ្វើសក្ខីកម្ម។ អនុលោមតាមវិធានការការពារណាមួយដែលអាចត្រូវចេញ សេចក្តីសង្ខេបគួរមានលក្ខណៈរៀបរាប់គ្រប់គ្រាន់ដើម្បីឱ្យអង្គជំនុំជម្រះសាលាដំបូង និងភាគីដទៃទៀតវាយតម្លៃខ្លស់ និងយល់បាននូវលក្ខណៈ និងខ្លឹមសារនៃការធ្វើសក្ខីកម្មដែលបានស្នើសុំធ្វើនោះ (ii) ចំណុចនានានៃការចោទប្រកាន់ដែលសាក្សីគ្រប់រូបរំពឹងថានឹងធ្វើសក្ខីកម្ម រួមទាំងកថាខណ្ឌ និងបទចោទជាក់លាក់”។

21. ការខកខានមិនបានបង្ហាញពីទំនាក់ទំនងនេះដោយភាគីណាមួយ ពុំមែនជាការខកខានរបស់អង្គជំនុំជម្រះក្នុងការ “ យល់[...] ការការពារខ្លួនរបស់មេធាវីការពារក្តី”[43]។ ការលើកឡើងជាប្រយោលក្នុងសារណាថា អង្គជំនុំជម្រះ “ពុំទាន់យល់ពីផលវិបាកនៃអង្គហេតុ និងអង្គច្បាប់នៃការការពារខ្លួនរបស់មេធាវីការពារក្តី ហើយហេតុនេះទំនងជាមិនទាន់យល់ពីការការពារខ្លួនរបស់ មេធាវីការពារក្តីតែម្តង”[44] ពុំមានមូលដ្ឋានទេ។

22. សហមេធាវីនាំមុខទទួលស្គាល់ថា សារណានេះបញ្ជាក់ថានឹងផ្តោតត្រឹមតែ “ការកំណត់អំពីទំនាក់ទំនងរវាងភស្តុតាងបែបនេះ ក្នុងអត្ថន័យទូទៅ ជាមួយកថាខណ្ឌនានានៃដីកាដំណោះស្រាយ [និង] មិនដោះស្រាយ[...] លម្អិតអំពីទំនាក់ទំនងរវាងភស្តុតាងរបស់សាក្សីនីមួយៗ ជាមួយដីកាដំណោះស្រាយឡើយ ដោយយល់ឃើញថា ចំណុចនេះមិនមែនជាលក្ខខណ្ឌតម្រូវទេ”[45]។ ទោះយ៉ាងនេះក្តីដោយកត់សម្គាល់ថា សំណើសុំការបញ្ជាក់កើតចេញពីពាក្យសុំរបស់មេធាវីការពារក្តី នួន ជា អនុលោមតាមវិធាន ៨៧(៤) សុំឱ្យទទួលយកភស្តុតាងបន្ថែម និងវិធាន ៩៣ សុំបំពេញកិច្ចស៊ើបសួរបន្ថែម[46] ជាការចាំបាច់ត្រូវភ្ជាប់ទំនាក់ទំនងរវាងភស្តុតាងបន្ថែមនេះ ជាមួយនឹងការចោទប្រកាន់លើអង្គហេតុក្នុងដីកាដំណោះស្រាយ។ កាបញ្ជាក់អំពី “ការការពារខ្លួនរបស់មេធាវីការពារក្តី” គឺជាការពុំចាំបាច់ទេ។

23. សហមេធាវីនាំមុខអះអាងថា ពាក្យ “បាបពីកំណើត” ដែលយោងទៅសារណារបស់ខ្លួន ក្នុងអំឡុងកិច្ចនីតិវិធីលើការបំបែកសំណុំរឿង ជួយតិចតួចដល់ការជំរុញសំណុំរឿងនេះ បើទោះជានេះជាកំហុសឆ្គងក៏ដោយ។ សហមេធាវីនាំមុខសូមទាញចំណាប់អារម្មណ៍ទៅលើអនុស្សរណៈអន្តរ

---

[43] សារណា កថាខណ្ឌ ៩។

[44] សារណា កថាខណ្ឌ ៩។

[45] សារណា កថាខណ្ឌ ១៦។

[46] សំណើសុំការបញ្ជាក់បំភ្លឺ, កថាខណ្ឌ ១ *យោង* សំណើរបស់ នួន ជា អនុលោមតាមវិធាន ៨៧(៤) សុំកោះហៅសាក្សីបន្ថែម និងសំណើអនុលោមតាមវិធាន ៩៣ សុំបំពេញកិច្ចស៊ើបសួរបន្ថែមទាក់ទងនឹងវគ្គសវនាការក្នុងសំណុំរឿង០០២/០២ ទាក់ទងនឹងមន្ទីរសន្តិសុខ ស២១ និងការបោសសម្អាតផ្ទៃក្នុង”, ឯកសារ E391, ថ្ងៃទី ២៤ ខែ មីនា ឆ្នាំ ២០១៦។ សំណើលើកទីពីរស្នើសុំសាក្សីសម្រាប់សំណុំរឿង ០០២/០២ ទាក់ទងនឹងផ្នែកមន្ទីរសន្តិសុខ និង “ការបោសសម្អាតផ្ទៃក្នុង” (មេដឹកនាំ), ឯកសារ E392 ថ្ងៃទី ១ ខែ មេសា ឆ្នាំ ២០១៦។ សំណើទីបីរបស់ នួន ជា សុំកោះហៅសាក្សីសម្រាប់សវនាការលើសំណុំរឿង ០០២/០២ លើប្រធានបទស្តីពីមន្ទីរសន្តិសុខ និងការបោសសម្អាតផ្ទៃក្នុង (ភស្តុតាងអំពីការបះបោរក្បត់), ឯកសារ E395, ថ្ងៃទី ១១ ខែ មេសា ឆ្នាំ ២០១៦។

ការិយាល័យដែលការិយាល័យសហចៅក្រមស៊ើបអង្កេតបានដាក់ ដែលបានឆ្លើយតបទៅមេធាវីការពារក្តី នួន ជា ពាក់ព័ន្ធនឹងការអនុវត្តកិច្ចស៊ើបសួរ៖

> "ជាថ្មីម្តងទៀត វាទំនងជាមានសារៈសំខាន់ក្នុងការបែងចែកឲ្យដាច់ពីគ្នារវាងប្រព័ន្ធច្បាប់កំពុងអនុវត្តនៅទីនេះ និងប្រព័ន្ធច្បាប់អន្តរជាតិ និង common law។ នៅចំពោះមុខយុត្តាធិការនេះ អំណាចក្នុងការ ស៊ើបអង្កេតត្រូវប្រគល់ឲ្យតែសហចៅក្រមស៊ើបអង្កេតឯករាជ្យពីររូបប៉ុណ្ណោះ ហើយមិនឲ្យទៅភាគីឡើយ។ មិនមានបទប្បញ្ញត្តិណាមួយដែលអនុញ្ញាតអោយភាគីបំពេញកិច្ចការស៊ើបអង្កេត ជំនួសសហចៅក្រមស៊ើបអង្កេត ដូចករណីនៅក្នុងប្រព័ន្ធនីតិវិធីផ្សេងទៀតនោះទេ។ ជាការពិត យោងតាមវិធាន ៥៥-១០ និង ៥៨-៦ ភាគីមានសិទ្ធិស្នើសុំទៅសហចៅក្រមស៊ើបអង្កេតឲ្យធ្វើកិច្ចស៊ើបសួរណាមួយបាន ហើយប្រសិនបើសហចៅក្រមស៊ើបអង្កេតដែលមិនយល់ព្រមតាមការស្នើសុំនេះ ត្រូវចេញដីកាបដិសេធមួយក្នុងរយៈពេលយ៉ាងយូរបំផុតមុនពេលបញ្ចប់នៃការស៊ើបអង្កេត ហើយដីកានេះអាចត្រូវប្តឹងឧទ្ធរណ៍បាន។ លទ្ធភាពរបស់ភាគីក្នុងការចូលពាក់ព័ន្ធគឺត្រូវបានកំហិតនៅត្រឹមការស្នើសុំដំបូងនេះ ដែលជាការចាំបាច់ក្នុងការអនុវត្តសិទ្ធិរបស់ខ្លួនប្រកបដោយប្រសិទ្ធភាព ក្នុងការស្នើសុំឲ្យមានកិច្ចស៊ើបសួរ"[47]។

24. ទោះជាវាអាចជាផ្នែកមួយនៃយុទ្ធសាស្រ្តរបស់មេធាវីការពារក្តី នួន ជា ក្នុងការជំទាស់ទៅនឹងប្រព័ន្ធ ដែលពួកគាត់បំពេញការងារនោះ ដែលជា នីតិវិធីច្បាប់ civil law កម្ពុជាក៏ដោយ ក៏សហមេធាវីនាំមុខមិនអាចផ្តល់យោបល់អំពីជម្រើសនៃប្រព័ន្ធច្បាប់ដែល អ.វ.ត.ក បំពេញការងារឡើយ។ យ៉ាងណាក៏ដោយ ពួកគាត់លើកឡើងថា យុទ្ធសាស្រ្តនេះពុំចងកាតព្វកិច្ចចំពោះភាគី និងអង្គជំនុំជម្រះសាលាដំបូងឡើយ។ ហេតុនេះ ចំពោះសំណើដែលប៉ះពាល់សិទ្ធិភាគីដទៃ វាមិនមែនជា ការងារច្រើនទេក្នុងការតម្រូវឲ្យបំពេញលក្ខខណ្ឌនៅក្នុងប្រព័ន្ធជាធរមាន ដើម្បីជំរុញឲ្យមានការជជែកដេញដោលដ៏មានអត្ថន័យឡើយ។

---

[47] ចម្លើយតបលិខិតរបស់លោកចុះថ្ងៃទី ២០ ខែ ធ្នូ ឆ្នាំ ២០០៧ ពាក់ព័ន្ធការបំពេញកិច្ចស៊ើបសួរ ឯកសារ A110/1, ថ្ងៃទី ១០ ខែ មករា ឆ្នាំ ២០០៨ កថាខណ្ឌ ៣។ *សូមមើលផង* សេចក្តីសម្រេចលើសំណើសុំរបស់ក្រុមមេធាវីការពារក្តី ពាក់ព័ន្ធនឹងភាពមិនប្រក្រតីដែលតាមការចោទប្រកាន់ថាបានកើតឡើងនៅក្នុងអំឡុងពេលនៃកិច្ចស៊ើបសួរ (ឯកសារ E221, E223, E224, E224/2, E234, E234/2, E241 និង E241/1), ឯកសារ E251, ថ្ងៃទី ៧ ខែ ធ្នូ ឆ្នាំ ២០១២, ទំព័រ ១៩ ដែលអង្គជំនុំជម្រះសាលាដំបូងសម្រេចថាមេធាវីការពារក្តី "ត្រូវបានហាមឃាត់មិនឲ្យបើកកិច្ចស៊ើបសួរនានា ហើយការបំពានណាមួយលើបទបញ្ញត្តិនេះ អាចនាំឲ្យមានការដាក់ទណ្ឌកម្មលើក្រុមមេធាវីការពារក្តី"។

25. ដូចដែលបានពិភាក្សាលម្អិតខាងដើម ទំនាក់ទំនងរវាងភស្តុតាង និងការចោទប្រកាន់លើអង្គហេតុ ផ្ទាប់ជា ហើយតែងតែជាបុរេលក្ខខណ្ឌសម្រាប់ការទទួលយកភស្តុតាងសម្រាប់សំណុំរឿង។ សហមេធាវីនាំមុខអះអាងថា ដោយសារតែគ្មានការបង្ហាញពីទំនាក់ទំនងនេះ សូម្បីតែនៅដំណាក់កាលនេះក៏ដោយ ពួកគាត់ត្រូវបានកំហិតក្នុងការឆ្លើយតបទៅនឹងវិសាលភាពនៃភស្តុតាងដែលបានស្នើសុំ។ ទោះយ៉ាងណាក៏ដោយ សហមេធាវីនាំមុខសូមឆ្លើយតបដូចខាងក្រោមទៅនឹងអង្គសេចក្តីនៃទំនាក់ទំនងដែលសារណានេះមាន។

**(គ) សេចក្តីសង្កេតស្តីពីផ្នែកសេសសល់នៃសារណា**

26. កថាខណ្ឌ ១៧ ព្យាយាមបង្កើតទំនាក់ទំនងរវាងភស្តុតាងរបស់ ឌុច ជាមួយនឹង "ភស្តុតាងនៃការបះបោរក្បត់ប្រឆាំង ប.ក.ក និងរដ្ឋាភិបាលកម្ពុជាប្រជាធិបតេយ្យដែលគាំទ្រដោយវៀតណាម" ដើម្បីបង្ហាញថា ស២១ និងមន្ទីរសន្តិសុខដទៃ គឺជាឧបករណ៍សន្តិសុខរដ្ឋជាប្រចាំ "ខុសពីមជ្ឈមណ្ឌលធ្វើទារុណកម្ម និងសម្លាប់"[48]។ សារណានេះបន្ថែមទៀតថា ភស្តុតាងនេះនឹងបង្ហាញ "ពីអង្គហេតុជាច្រើនដែលកំពុងមានបញ្ហានៅក្នុងផ្នែកសវនាការនេះក្នុងទិដ្ឋភាពផ្សេងៗគ្នា"[49]។ សហមេធាវីនាំមុខពុំអាចឆ្លើយតបបានទេ ពីព្រោះអាចមានការលើកឡើងមិនត្រឹមត្រូវក្នុងការយោងទៅដីកាដំណោះស្រាយ[50]។ ពាក្យ "មជ្ឈមណ្ឌលធ្វើទារុណកម្ម និងសម្លាប់" ដែលត្រូវបានលើកឡើងក្នុងសារណាថាចេញពីដីកាដំណោះស្រាយ ពុំមានឡើយ មិនតែក្នុងកថាខណ្ឌនានាដែលត្រូវបានដកស្រង់ក្នុងសារណានេះឡើយ តែក៏មិនមាននៅចំណុចណាមួយក្នុងដីកាដំណោះស្រាយដែរ។

---

[48] សារណា កថាខណ្ឌ ១៧។

[49] *ដូចឯកសារយោងខាងលើ*។

[50] សារណា ជើងទំព័រ៤២*យោង*ដីកាដំណោះស្រាយ កថាខណ្ឌ ១៣៩, ៤៥៥។ ប្រៀបធៀបជាមួយការចោទប្រកាន់លើអង្គហេតុដែលមានក្នុងដីកាដំណោះស្រាយ កថាខណ្ឌ ១៣៩៖ "និរសារក៏ត្រូវបានប្រើប្រាស់ជាញឹកញាប់ដើម្បីនាំសារ។ កងពល នីមួយៗមានអង្គភាពនិរសារដើម្បីផ្តល់សេវាទាំងនេះ" កថាខណ្ឌ ៤៥៥ "មុខងារចម្បងរបស់ ស២១ គឺទាញយកចម្លើយសារភាពពីអ្នកជាប់ឃុំឃាំងដែលជួយវែកមុខបណ្តាយដទៃទៀតនៃជនក្បត់សក្តានុពល។ ឌុច និយាយថា "ខ្លឹមសារនៃចម្លើយសារភាពជាកិច្ចការសំខាន់បំផុតរបស់ ស២១"។ ជារឿយៗ ចម្លើយសារភាពទាំងនេះមានទម្រង់ជាប្រវត្តិរូបនយោបាយដែលសរសេរដោយអ្នកជាប់ឃុំឃាំងដែលក្រោមការបង្ខិតបង្ខំឆ្លើយសារភាពថាក្បត់ និងឆ្លើយដាក់ជនក្បត់ដទៃដែលធ្វើការឲ្យសេវាសម្ងាត់របស់មហាអំណាចដែលចាត់ទុកជាសត្រូវរបស់បដិវត្តន៍កម្ពុជា។ ការពិត ដែលថាចម្លើយសារភាពទាំងនេះត្រូវបានសន្មតថា លាតត្រដាងគឺក្នុងករណីជាច្រើនត្រូវបានកំណត់ជាមុន ពីព្រោះអ្នកសួរចម្លើយដែលត្រូវបានឌុចណែនាំឲ្យបង្ហាញអត្ថិភាពនៃទំនាក់ ទំនងជាមួយសេអ៊ីអា កាហ្សេបេ ឬវៀតណាម បានបង្ខំអ្នកជាប់ឃុំឲ្យផ្តល់ចម្លើយដែលបានកំណត់ទុកជាមុន" (យោងផ្ទៃក្នុងលុបចោល) [translation]។

27. កថាខណ្ឌ ១៨ មានការសន្និដ្ឋានជាទូទៅថា “មនុស្សជាច្រើនដែលត្រូវបានដាក់ក្នុងមន្ទីរឃុំឃាំង និងដាក់ឲ្យទៅជាទាសករនោះ បានចូលទៅក្នុងមន្ទីរសន្តិសុខដោយសារតែ “ការបោសសម្អាតផ្ទៃក្នុង” នៅភូមិភាគបូព៌ា ភូមិភាគឧត្តរថ្មី និងឧត្តរចាស់”។ សហមេធាវីនាំមុខសូមអះអាងថា ការសន្និដ្ឋានជាទូទៅចំពោះការចោទប្រកាន់លើអង្គហេតុ ធ្វើឲ្យមានការពិនិត្យឃើញអំពីហានិភ័យនៃការលើកឡើងមិនត្រឹមត្រូវ។ សហមេធាវីនាំមុខសូមបញ្ជាក់ថា មន្ទីរសន្តិសុខដែលឆ្លើយតបទៅនឹងភូមិភាគឧត្តរ និងភូមិភាគបូព៌ា ពុំស្ថិតក្នុងវិសាលភាពនៃសំណុំរឿង០០២/០២ ទេ។ មន្ទីរសន្តិសុខក្រាំងតាចាន់ពាក់ព័ន្ធនឹងភូមិភាគនិរតី[51]។ មន្ទីរសន្តិសុខអូរកន្សែងពាក់ព័ន្ធនឹងភូមិភាគឦសាន[52]។ មន្ទីរសន្តិសុខភ្នំក្រោលស្ថិតក្នុងភូមិភាគនិរតី និងក្រោយមក ស្ថិតក្រោមតំបន់ស្វយ័ត ដូច្នេះស្ថិតក្រោមការគ្រប់គ្រងផ្ទាល់របស់មជ្ឈិមបក្ស[53]។ ទោះជាអាចជាការពិតថា បុគ្គលនានាពីភូមិភាគឧត្តរ និងភូមិភាគបូព៌ាបានចូលទៅមន្ទីរ ស២១ ក៏ដោយ[54] ក៏វាមិនមែនជាការត្រឹមត្រូវ ពិតប្រាកដដែលលើកឡើងថា ដីកាដំណោះស្រាយលើកឡើងថា មនុស្សជាច្រើនដែលត្រូវបានឃុំឃាំងនៅមន្ទីរសន្តិសុខដែលបានលើកខាងលើ ស្ថិតនៅទីនោះដោយសារតែគាត់ជាគោលដៅនៃគោលនយោបាយបោសសម្អាតផ្ទៃក្នុង ក្នុងភូមិភាគឧត្តរ និងភូមិភាគបូព៌ាឡើយ។

28. កថាខណ្ឌ ២២ នៃដីកាសារណានេះអះអាងថា ភស្តុតាងពីរប្រភេទ គាំទ្រដល់ទ្រឹស្តីរបស់ពួកគាត់អំពីការបះបោរក្បត់នោះ គឺ (i) ខ្លឹមសារសំខាន់នៃចម្លើយសារភាពពីមន្ទីរ ស២១ និង (ii) ភស្តុតាងផ្ទាល់របស់សាក្សីចំនួន ៣៥ នាក់ដែលត្រូវបានស្នើឡើងនោះ។ កថាខណ្ឌនេះលើកទឡ្ហីករណ៍ថា អង្គជំនុំជម្រះសាលាដំបូងហាក់ដូចជាបានដាក់ “ការហាមឃាត់រួម” នៅក្នុង “សេចក្តីសម្រេចដែលលម្អៀងខ្លាំង ដែលមិនអាចយល់បាន” របស់ខ្លួន ដែល “រំលោភដល់សេចក្តីសម្រេចរបស់តុលាការកំពូលដែលបានអនុញ្ញាតឲ្យភាគីប្រើប្រាស់ខ្លឹមសារនៃចម្លើយសារភាព ដើម្បីបង្ហាញថា ព័ត៌មាននៅក្នុងសំណួរ គឺមិនមែនបានមកដោយការធ្វើទារុណកម្មនោះទេ”។ ទីមួយ សហមេធាវីនាំមុខអះអាងថា មេធាវីការពារក្តី នួន ជា វាយតម្លៃមិនត្រឹមត្រូវទៅលើសេចក្តីសម្រេចរបស់អង្គ

[51] ដីកាដំណោះស្រាយ កថាខណ្ឌ ៤៨៩។

[52] ដីកាដំណោះស្រាយ កថាខណ្ឌ ៥៨៩។

[53] ដីកាដំណោះស្រាយ កថាខណ្ឌ ៦២៥។

[54] ដីកាដំណោះស្រាយ កថាខណ្ឌ ១៩៦ ១៩៩។

ជំនុំជម្រះសាលាដំបូង[55]។ សេចក្ដីសម្រេចនេះបានអនុញ្ញាតឲ្យប្រើប្រាស់ចម្លើយ “លើកលែងតែនៅក្នុងកាលៈទេសៈមានកម្រិតដែលត្រូវបានអនុញ្ញាតដោយអង្គជំនុំជម្រះនៅក្នុងសេចក្ដីសម្រេចរបស់អង្គជំនុំជម្រះ លើភស្តុតាងដែលបានមកដោយការធ្វើទារុណកម្ម”[56]។ ក្នុងន័យនេះ បទដ្ឋាននេះមិនខុសពីបទដ្ឋានដែលបង្កើតឡើងដោយអង្គជំនុំជម្រះតុលាការកំពូលឡើយ[57]។ ទីពីរ សហមេធាវីនាំមុខសូមរម្លឹកថា មេធាវីការពារក្ដី នួន ជា បានប្រើប្រាស់មធ្យោបាយនីតិវិធីត្រឹមត្រូវដើម្បីបង្ហាញកាលៈទេសៈ ដែលបដិសេធហានិភ័យពិតប្រាកដនៃការធ្វើទារុណកម្ម សម្រាប់ឲ្យអង្គ

---

[55] សេចក្ដីសម្រេចលើភស្តុតាងដែលបានមកដោយការធ្វើទារុណកម្ម, ឯកសារ E350/8, ថ្ងៃទី ៥ ខែ កុម្ភៈ ឆ្នាំ ២០១៦ កថាខណ្ឌ ៣៦៖ “បន្ទាប់ពីអង្គជម្រះចេញសេចក្ដីសម្រេចជាបឋមថាមានហានិភ័យពិតប្រាកដមែនដែលថាអំពើទារុណកម្មត្រូវបានប្រើប្រាស់ដើម្បីបានចម្លើយសារភាពនោះ <u>ភាគីណាដែលស្នើការប្រើប្រាស់ភស្តុតាងនោះអាចជំទាស់ការសម្រេចបឋមនេះ ជាពិសេសបន្ទាប់ពីបង្ហាញកាលៈទេសៈជាក់លាក់ផ្សេងៗដែលបដិសេធពីហានិភ័យនោះ</u>”។ (សេចក្ដីបញ្ជាក់បន្ថែម)។ ផ្នែកសម្រេចសេចក្ដីគូសបញ្ជាក់ថា “ចម្លើយសារភាពពីមន្ទីរសន្តិសុខនានាដែលសហចៅក្រមស៊ើបអង្កេតបានកំណត់ថាមានការប្រើអំពើទារុណកម្មស្ថិតក្នុងវិសាលភាពមាត្រា១៥ នៃ CAT ដូច្នេះហើយ អាចមិនត្រូវបានអនុញ្ញាតឲ្យប្រើក្នុងកិច្ចដំណើរការនីតិវិធីនេះទេ លើកលែងតែមានករណីជាក់ស្ដែងណាមួយដែលបង្ហាញថាចម្លើយសារភាពនោះ មិនមែនបានពីការធ្វើទារុណកម្ម ឬថាភស្តុតាងនោះត្រូវបានប្រើប្រាស់អនុលោមតាមអញ្ញត្រកម្មដែលមានក្នុងមាត្រា ១៥”។ *សូមមើលបន្ថែម* សេចក្ដីសម្រេចលើសំណើរបស់ នួន ជា សុំប្រើប្រាស់ចម្លើយមួយចំនួនពីមន្ទីរសន្តិសុខ ស២១ អនុលោមតាមវិធាន ៩២ នៃវិធានផ្ទៃក្នុង, ឯកសារ E399/4, ថ្ងៃទី ១៩ ខែ ឧសភា ឆ្នាំ ២០១៦ កថាខណ្ឌ ២ “ហេតុដូច្នេះអង្គជំនុំជម្រះសាលាដំបូងសម្រេច៖ ក. បដិសេធសំណើសុំអនុញ្ញាតប្រើប្រាស់ចម្លើយពីមន្ទីរសន្តិសុខ ស២១ របស់ កុយ ធួន យឹម សម្បត្តិ និង ជា នន់ លើកលែងតែក្នុងកាលៈទេសៈមានកម្រិតដែលត្រូវបានអនុញ្ញាតដោយអង្គជំនុំជម្រះនៅក្នុងសេចក្ដីសម្រេចរបស់ខ្លួនលើភស្តុតាងដែលបានមកដោយការធ្វើទារុណកម្ម (E350/8)”។

[56] អនុស្សរណៈរបស់អង្គជំនុំជម្រះសាលាដំបូងដែលមានចំណងជើង សេចក្ដីសម្រេចលើសំណើរបស់ នួន ជា សុំប្រើប្រាស់ចម្លើយមួយចំនួនពីមន្ទីរសន្តិសុខ ស២១ អនុលោមតាមវិធាន៩២នៃវិធានផ្ទៃក្នុង, ឯកសារ E399/4, ថ្ងៃទី ១៩ ខែ ឧសភា ឆ្នាំ ២០១៦ កថាខណ្ឌ២។

[57] សេចក្ដីសម្រេចលើសេចក្ដីជំទាស់ទៅនឹងបញ្ជីឯកសារសំអាងហេតុពេញលេញ, ឯកសារ F26/12, ថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០១៥ កថាខណ្ឌ ៥៨៖ “ភាគីណាដែលសុំផ្អែកលើចម្លើយនៅមន្ទីរស២១ គប្បីត្រូវបានអនុញ្ញាតឲ្យជំទាស់ការសន្មតនេះដោយផ្ដល់ភស្តុតាងបញ្ជាក់ថាព័ត៌មានដែលចោទជាបញ្ហានេះពុំមែនជាលទ្ធផលនៃការធ្វើទារុណកម្មឡើយ។ យោងតាមសំអាងហេតុខាងលើ នៅពេលសម្រេចលើបញ្ហានេះអង្គជំនុំជម្រះចាំបាច់ត្រូវពិចារណាលើព័ត៌មានពាក់ព័ន្ធដែលខ្លួនបានដឹងបន្ថែមលើសារណារបស់ភាគី។ ជាចុងក្រោយ ចម្លើយនៅមន្ទីរស២១ អាចត្រូវបានទទួលយកជាភស្តុតាងតែក្នុងករណីដែលចម្លើយនេះបានបង្ហាញឲ្យឃើញថាផ្អែកលើបទដ្ឋានស្ដីពីតុល្យភាពនៃភវនីយភាព *ពុំមែន* ជាលទ្ធផលនៃការធ្វើទារុណកម្មឡើយ”។ សហមេធាវីនាំមុខកត់សម្គាល់ឃើញថាបទដ្ឋានកំណត់ដោយអង្គជំនុំជម្រះតុលាការកំពូលមានភាពរិតត្បិតជាង ត្រង់ចំណុចដែលមិនអនុញ្ញាតសូម្បីតែការទទួលយកជាភស្តុតាងនូវឯកសារដែលត្រូវបានបញ្ជាក់ថាបានមកពីការធ្វើទារុណកម្ម។

ជំនុំជម្រះសាលាដំបូងពិចារណា[58]។ ទីបី សហមេធាវីនាំមុខកត់សម្គាល់ឃើញថា គ្មាន "បញ្ហាភ័ស្តុតាង" ដែលសាក្សី ៣៥ នាក់ដែលត្រូវបានស្នើសុំ នឹងបំពេញជាមធ្យោបាយ "ដើម្បីបញ្ជាក់អំពីអត្ថិភាពនៃទំនាក់ទំនងជាក់លាក់រវាងកាលបរិច្ឆេទ និងទីតាំងនៃការរៀបចំដែលត្រូវ បានបង្ហាញ និងការប៉ុនប៉ងបះបោរក្បត់ និងការចាប់ខ្លួន និងឃុំខ្លួនមនុស្សនៅតាមមន្ទីរសន្តិសុខ ពាក់ព័ន្ធ"។ មេធាវីការពារក្តី នួន ជា ពុំត្រូវបានរារាំងមិនឱ្យប្រើប្រាស់ព័ត៌មានសត្យានុម័តដែល មានក្នុងចម្លើយពីមន្ទីរ ស២១ ដើម្បីទទួលបានព័ត៌មានប្រភេទនេះ ដូចដែលអង្គជំនុំជម្រះសាលាដំបូងបានលើកឡើងក្នុងសេចក្តីសម្រេចរបស់ខ្លួនលើភស្តុតាងដែលបានមកដោយការធ្វើទារុណ កម្ម[59]។

29. កថាខណ្ឌ ២៥ ភ្ជាប់ជំហររបស់មេធាវីការពារក្តី នួន ជា អំពីការឃុំឃាំង "ជនជាតិវៀតណាម" នៅ "មន្ទីរស២១ និងមន្ទីរសន្តិសុខអូរកន្សែង" ទៅនឹងឧក្រិដ្ឋកម្មសំខាន់ដែលត្រូវបានចោទប្រកាន់អំពីការឃុំខ្លួនជនស៊ីវិលដោយខុសច្បាប់ ដែលជាការរំលោភធ្ងន់ធ្ងរលើអនុសញ្ញាក្រុងហ្សឺណែវ។ ត្រង់ចំណុចដែលខ្លឹមសារនៃកថាខណ្ឌនេះទាក់ទងនឹងការបង្ហាញជំហរពាក់ព័ន្ធនឹងធាតុផ្សំមួយ ឬច្រើននៃឧក្រិដ្ឋកម្មសំខាន់ សហមេធាវីនាំមុខអះអាងថា ចំណុចនេះពុំបង្កើនលទ្ធភាពរបស់ភាគីក្នុងការឆ្លើយតបទៅនឹងវិសាលភាពនៃភស្តុតាងថ្មីដែលត្រូវបានស្នើសុំឱ្យទទួលយកឡើយ។ លើសពីនេះទៀត សហមេធាវីនាំមុខសូមបញ្ជាក់ថា នួន ជា ពុំត្រូវបានចោទប្រកាន់ពីបទល្មើសជាក់លាក់នៃការឃុំឃាំងជនស៊ីវិលដោយខុសច្បាប់ ដែលជាការរំលោភធ្ងន់ធ្ងរលើអនុសញ្ញាក្រុងហ្សឺណែវ ចំពោះករណីមន្ទីរសន្តិ សុខអូរកន្សែងឡើយ[60]។

30. ជាការឆ្លើយតបទៅនឹងកថាខណ្ឌ ៣១-៣៨ សហមេធាវីនាំមុខពុំជំទាស់ទៅនឹងការមិនបញ្ចូលការទទួលខុសត្រូវព្រហ្មទណ្ឌពីសំណុំរឿង ០០២/០១ ទៅសំណុំរឿង ០០២/០២ ទេ។ ប៉ុន្តែ ទោះជាមានការភ្ជាប់គ្នាក្នុងសារណានេះ រវាងរចនាសម្ព័ន្ធ ប.ក.ក ជាមួយសហឧក្រិដ្ឋកម្មរួម[61] សហមេធាវីនាំមុខកត់សម្គាល់ឃើញថា វគ្គសវនាការស្តីពី "តួនាទីរបស់ជនជាប់ចោទ/សហឧក្រិដ្ឋកម្ម

---

[58] សំណើរបស់ នួន ជា អនុលោមតាមវិធាន ៩២ នៃវិធានផ្ទៃក្នុងសុំប្រើប្រាស់ចម្លើយសារភាព ស២១ មួយចំនួន, ឯកសារ E399, ថ្ងៃទី ២០ ខែ មេសា ឆ្នាំ ២០១៦។

[59] សេចក្តីសម្រេចលើភស្តុតាងដែលបានមកដោយការធ្វើទារុណកម្ម, ឯកសារ E350/8, ថ្ងៃទី ៥ ខែ កុម្ភៈ ឆ្នាំ ២០១៦ កថាខណ្ឌ ៥៩។

[60] ដីកាដំណោះស្រាយ កថាខណ្ឌ ១៥១៨-១៥២០។

[61]

រួម” នឹងត្រូវធ្វើឡើងនៅពេលខាងមុខ[62] ដែលនៅពេលនោះ ភស្តុតាងបែបនេះនឹងត្រូវពិចារណា និងពិនិត្យដេញដោលដោយភាគីទាំងអស់។

## IV. **សំណើ**

31. សហមេធាវីនាំមុខសូមស្នើដោយក្តីគោរពសុំឲ្យអង្គជំនុំជម្រះសាលាដំបូងពិចារណាទៅលើសេចក្តីសង្កេតនានាក្នុងចម្លើយតបនាពេលបច្ចុប្បន្ននៅពេលធ្វើការវិនិច្ឆ័យសំណើសុំសាក្សី និង/ឬកិច្ចស៊ើបសួរបន្ថែមសម្រាប់វគ្គសវនាការស្តីពីមន្ទីរសន្តិសុខ និងការបោសសម្អាតផ្ទៃក្នុង។

សូមលោក លោកស្រីចៅក្រមទទួលយកចម្លើយតបនេះដោយក្តីគោរពអំពីយើងខ្ញុំ

| កាលបរិច្ឆេទ | ឈ្មោះ | ទីកន្លែង | ហត្ថលេខា |
|---|---|---|---|
| ថ្ងៃទី ២០ ខែ មិថុនា ឆ្នាំ ២០១៦ | ពេជ អង្គ<br>សហមេធាវីនាំមុខ | ភ្នំពេញ | |
| | Marie GUIRAUD<br>សហមេធាវីនាំមុខ | ភ្នំពេញ | |

[62] សេចក្តីសម្រេចស្តីពីលំដាប់លំដោយនៃអង្គហេតុដែលត្រូវជំនុំជម្រះនៅក្នុងសំណុំរឿង ០០២/០២, ឯកសារ E315, ថ្ងៃទី ១២ ខែ កញ្ញា ឆ្នាំ ២០១៤។